ធាវ - ឆែសុត

# សិក្សា
# វប្បធម៌_អរិយធម៌
# ខ្មែរ_ឥណ្ឌា



ស្របតាម

កម្មវិធីសិក្សាថ្មី

សម្រាប់

ថ្នាក់ទីបញ្ចប់ និង

ថ្នាក់ត្រៀមឧត្តមសិក្សា

CA 32

ធាវ៉ា - វ៉ានសុភ

សាស្ត្រាចារ្យ បរិញ្ញា

វិទ្យាល័យ ទួលគោក

សិក្សា

# ទស្សនវិជ្ជា អរិយធម៌

ខ្មែរ - ឥណ្ឌា

សម្រាប់

ថ្នាក់ទីបញ្ចប់ និង ថ្នាក់ត្រៀមឧត្តមសិក្សា

ឆ្នាំសិក្សា ១៩៧១ - ៧២

# អារម្ភកថា

គ្រប់ប្រទេសទាំងអស់ក្នុងលោក សុទ្ធតែមានគោលការណ៍ វប្បធម៌ អរិយធម៌ ប្រចាំប្រទេសជាតិ ។ គេអាចដឹងស្គាល់ប្រទេសជាតិ ណាមួយ ចំរើនលូតលាស់មានវឌ្ឍនភាព ជាអរិយប្រទេស ឬ ទន់ខ្សោយមានឧនភាព ជាអនារិយប្រទេស ដោយសារតែវប្បធម៌ អរិយធម៌ ប្រទេសជាតិនោះឯង ។

រីឯខ្មែរវិញ ក៏មានវប្បធម៌ អរិយធម៌ ជាគោលការណ៍ ប្រចាំជាតិ ខ្មែរ ប្រទេសខ្មែរដែរ ។ ក្នុងករណីនេះ ខ្មែរគ្រប់រូប ចាំបាច់ត្រូវតែចេះ ដឹងយល់ស្គាល់ដោយច្បាស់លាស់ នូវវប្បធម៌ អរិយធម៌ ជាតិខ្លួន ប្រទេសខ្លួន អំពីតម្លៃ ផលប្រយោជន៍ កំណាក់កំណើត ប្រភព និងលក្ខណៈផ្ទាល់នៃ វប្បធម៌ អរិយធម៌ ជាតិ ។

មិនតែប៉ុណ្ណោះ ខ្មែរគ្រប់រូប គប្បីនាំគ្នានិយមជួយលើកតម្កើង លើកស្ទួយវប្បធម៌ អរិយធម៌ជាតិដោយចំណុះចិត្តគំនិត អ្នកជាតិនិយម ខ្មែរនិយម ឲ្យបានជ្រួតជ្រាបទូទៅគ្រប់មជ្ឈដ្ឋាន នៃសង្គមខ្មែរ ។ ព្រមជាមួយនេះ ខ្មែរគ្រប់រូប មានករណីយកិច្ចចាំបាច់ ត្រូវសិក្សាស្រាវជ្រាវរកវិធី និងមធ្យោបាយ ផ្សព្វផ្សាយវប្បធម៌ អរិយធម៌ ខ្មែរ ឲ្យបានចំរើនលូតលាស់ ផុះផុលមានសន្ទុះ និងល្បឿន ស្របតាមដំណើរវិវត្តទៅនៃពិភពលោក ។

ខ្ញុំព្យាយាម ប្រមែប្រមូល រៀបរៀង ចងក្រងសៀវភៅ (វប្បធម៌ អរិយធម៌ខ្មែរ - ឥណ្ឌា) នេះដើម្បីបង្ហាញ អំពីមូលធម៌ និងទំនាក់ទំនងដែលជាទម្រមូលដ្ឋាន ទ្រទ្រង់វប្បធម៌ អរិយធម៌ខ្មែរ តម្រូវតាមសេចក្តីត្រូវការ

នៃសិក្ខាកាមជន ។

សូមអភ័យទោស អំពីសំណាក់អស់លោក អ្នកប្រាជ្ញ បណ្ឌិត បញ្ញវន្ត អ្នកជាតិនិយម ដែលបានចេះដឹង យល់ច្បាស់ អំពីវប្បធម៌ អរិយធម៌ជាតិ ចំពោះកំហុសដោយអចេតនា ។ សូមមេត្តាជួយកែតម្រូវ តាមការគួរ ។

សូមចិត្តគំនិតជាតិនិយមកើតមានគ្រប់ទិសទី !

សូមជួយតម្កើងវប្បធម៌ អរិយធម៌ជាតិ !

ធាវ - ឆៃសុភ

សាស្ត្រាចារ្យ បរិញ្ញា

# ឯកសារពិគ្រោះ

| | |
|---|---|
| វប្បធម៌ អរិយធម៌ខ្មែរ | កេង - វ៉ាន់សាក់ |
| វេទនិយម | ប៉ាង - ខាត់ |
| វេទបញ្ញត្តិ | ប៉ាង - ខាត់ |
| ទស្សនវិជ្ជា ពុទ្ធសាសនា | ប៉ាង - ខាត់ |
| ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ | ប៉ាង - ខាត់ |
| វប្បធម៌ អរិយធម៌ខ្មែរ | លាង - ហាប់អាន |
| អំពីពុទ្ធសាសនា | ល៊ូ - ហ៊ួណូត |
| អរិយសច្ចកថា | អ៊ុំ - ស៊ូ |
| វប្បធម៌ អរិយធម៌ខ្មែរ | ស - សារុន |
| អំពីប្រាសាទខ្ទះ នៅអង្គរ | ហ៊ួត - តាត |
| សិល្បវិជ្ជា ផ្នែកសិល្បៈខ្មែរ | តៃ - ប៉ែងហាប់ |
| មគ្គុទ្ទេសក៍នគរវត្ត | ប៉ាង - ខាត់ |
| ពង្សតាស៊ីទ្វីប | ញ៉ុក - ថែម |

វប្បធម៌ ឥណ្ឌូ-ខ្មែរ មុំម - មុំន

Histoire ancienne des Etats Hindouisés d'Extrême-Orient G. Cœdès
Angkor, Hommes et Pierres Groslier
Guide du Musée National M. Giteau
Préface pour Angkor EF-EO
Nouveau guide d'Angkor H. Marchal
Les Monuments du Groupe d'Angkor M. Glaize
Histoire du Cambodge M. Giteau .

## សូមមេត្តាអភ័យទោស

នៅទំព័រទី ១២ - ១៣ អំពីតារាងបង្ហាញមែកធាងវប្បធម៌ បានកំហុសបច្ចេកទេសពេងពុម្ព ។ ត្រូវអានថា: វប្បធម៌ សង្គមធម៌ ។

សូមអរគុណ

# មាតិការឿង


| ឈ្មោះអត្ថបទ | ទំព័រ |
| --- | --- |
| សំនាំដើម | ១ |
| អត្ថន័យនៃពាក្យវប្បធម៌ | ៣ |
| អត្ថន័យនៃពាក្យអរិយធម៌ | ៦ |
| តារាងបង្ហាញមែកធាងអរិយធម៌ | ១២ |
| ឥទ្ធិពលអរិយធម៌ | ១៤ |
| ទស្សនៈលោក G. Cœdès | ២០ |
| ទស្សនៈលោក Groslier | ២៩ |
| មូលធាតុនៃអរិយធម៌ខ្មែរ | ៣៦ |
| វេទនិយម | ៣៩ |
| បញ្ហាពុទ្ធិភាវៈ សុខ ក្នុងលទ្ធិវេទ | ៤៤ |
| ព្រាហ្មណ៍និយម | ៤៧ |
| ព្រះព្រហ្ម | ៤៨ |
| ព្រះសិវៈ (ឥសូរ) | ៤៩ |
| សិវលិង្គ | ៥៤ |
| រូបសិវៈ | ៥៦ |
| ព្រះវិស្ណុ | ៥៧ |
| អវតារវិស្ណុ ១០ យ៉ាង | ៥៨ |
| រូបវិស្ណុ | ៦១ |
| វិធីប្រតិបត្តិនៃសាសនាព្រាហ្មណ៍ | ៦២ |
| ពិធីបូជាយៈ បូជាអគ្គិ | ៦៤ |

ឈ្មោះអត្ថបទ ទំព័រ


តបៈ ពេភគៈ ៧៣
សាសនាព្រាហ្មណ៍ និង សង្គមខ្មែរ ៧៩
ជំនឿ ៨០
ប្រពៃណី ទំនៀមទម្លាប់ ៨០
សិល្បៈ ៨២
អក្សរសិល្ប៍ ៨៦
លក្ខណៈអក្សរសិល្ប៍បែបព្រាហ្មណ៍និយម ៨៧
ពុទ្ធប្បវត្តិ ៩៤
ពុទ្ធលទ្ធិ ព្រះត្រៃបិដក ៩៩
បញ្ហាពុទ្ធិ ភវៈ សុខ ក្នុងពុទ្ធលទ្ធិ ១០៨
ពុទ្ធិៈ វិជ្ជា ៣ ប្រការ ១១១
អរិយសច្ច ៤ ១១៧
បដិច្ចសមុប្បាទ ១២៦
ពុទ្ធសាសនា និង សង្គមខ្មែរ ១២៩
ជំនឿ ១៣០
ប្រពៃណី ទំនៀមទម្លាប់ ១៣១
សិល្បៈ ១៣៤

# វប្បធម៌ អរិយធម៌ ខ្មែរ

## សំនាវដើម :

មនុស្សទាំងអស់ក្នុងលោក គ្រប់ជាតិ គ្រប់ប្រទេស តែងតែមានបំណងចង់ប្រាថ្នា ចង់ឲ្យប្រទេសជាតិរបស់ខ្លួន បានលូតលាស់ចំរុងចំរើនគ្រប់វិស័យ តាមល្បឿននៃវិទ្យាសាស្ត្រ ព្រោះគេបានចាត់ទុកវិទ្យាសាស្ត្រ ជាមធ្យោបាយដ៏សំខាន់ សម្រាប់ធ្វើឲ្យមនុស្ស បានគប់ប្រសព្វនឹងសុខសុភមង្គល ។

អ្នកប្រាជ្ញ បញ្ញវន្ត វិទ្យាវិទូ ទស្សនវិទូ ដែលជាអ្នកមនុស្សនិយម ជាតិនិយម បានខំរិះរកគ្រប់មធ្យោបាយ ចាត់គ្រប់វិធានការ ដើម្បីរៀបចំ រចនា សង្គមមនុស្សឲ្យបានប្រកបដោយ សុខ សន្តិភាព មានអរិយធម៌ខ្ពង់ខ្ពស់ ល្អប្រសើរ សមជាពលរដ្ឋនៃអរិយប្រទេសក្នុងពិភពលោកៗ ឯមធ្យោបាយ រៀបចំសង្គមមនុស្ស ទោះជាខាងវិទ្យា-

សាស្ត្រក្តី អក្សរសាស្ត្រក្តី សិល្បៈ អក្សរសិល្ប៍ក្តី តាំងអស់នេះ សុទ្ធតែមានទំនាក់ទំនង មានប្រភពចេញមកអំពីមូលដ្ឋានធំ គឺវប្បធម៌ អរិយធម៌ នានា ដែលបានឆ្លងកាត់គ្នាទៅវិញទៅមក អំពីប្រទេសមួយទៅប្រទេសមួយទៀត អំពីជាតិមួយទៅជាតិមួយ ។

រីឯវប្បធម៌ អរិយធម៌ខ្មែរ ក៏មានទំនាក់ទំនងនឹងប្រ-ទេសខ្លះដែរ ដូចជា ឥណ្ឌា បារាំង ចិន យួន សៀម លាវ ជាដើម ។ តែខ្មែរក៏ធ្លាប់ជាមហាប្រទេស មានវប្បធម៌ អរិយធម៌ ចំរើនរុងរឿងនាអតីតសម័យ ព្រមទាំងមានកិត្តិនាមល្បីល្បាញពេញពិភពលោក ដោយបានទុកកេរ្តិ៍ដំណែល សិលាប្រាសាទ អង្គរវត្តជាភស្តុតាង ដើម្បីបង្ហាញពិភពលោក ឲ្យបានឃើញប្រត្យក្ស ជាក់ច្បាស់នឹងនេត្រា ។

តើអ្វី ដែលហៅថា វប្បធម៌ អរិយធម៌ ?

# វប្បធម៌

**Culture**

## អត្ថន័យ

វប្បធម៌ មានន័យច្រើនបែបយ៉ាង ដែលឋិតនៅលើទស្សននិយម ផ្សេងៗគ្នា ។

–ទស្សនៈខ្លះ យល់ថា: វប្បធម៌គឺការផ្ដុំបណ្ដុះចំណេះវិជ្ជានិងប្រាជ្ញាស្មារតី ឲ្យល្អគណាស់ចំរុងចំរើន ដោយវិទ្យាសាស្ត្រ សិល្បៈ អក្សរសាស្ត្រ ជាដើម ។

ទស្សនៈខ្លះ យល់ថា: វប្បធម៌ គឺ ចំណេះចេះដឹងការសិក្សា ការអប់រំ ។

–ទស្សនៈខ្លះ យល់ថា: វប្បធម៌ គឺ ការសិក្សាពង្រីកវិជ្ជា ។

ទស្សនៈខ្លះ យល់ថា: វប្បធម៌គឺរឿងៗ ដែលទាក់ទងនឹងការសិក្សា ការអប់រំ ។

-ទស្សនៈខ្មែរ យល់ថា: វប្បធម៌គឺអ្វីៗ ដែលធ្វើឲ្យមានការចំរើនល្អគួរណាស់ គ្រប់វិស័យ ។

ដូច្នេះ តាមទស្សនៈខាងលើនេះ វប្បធម៌សំដៅយកការសិក្សា ការអប់រំ ចំណេះវិជ្ជា ការបណ្តុះប្រាជ្ញាស្មារតី

ប៉ុន្តែ វប្បធម៌ < វប្ប + ធម៌

វប្ប: Vappa : សំណាប ពង្រោះ លូតលាស់
ចំរើន ដុះដាល បណ្តុះបណ្តាល ។

ធម៌ Dharma : ទ្រឹស្តីឬ ធម៌ភាព នាំឆ្ពោះទៅរកវឌ្ឍន-
ភាព និងការអនុវត្តន៍យ៉ាងសកម្ម ។

ហេតុនេះ វប្បធម៌ គឺទ្រឹស្តី ឬ ធម៌ភាពទាំងឡាយដែលបណ្តុះបណ្តាលសេចក្តីចំរើន ប្រាជ្ញា និង ឧត្តមគតិដ៏ប្រសើរខ្ពង់ខ្ពស់របស់មនុស្ស ធ្វើឲ្យមានការចំរើនល្អគួរណាស់ ក្នុងសង្គមមនុស្ស ដោយវិជ្ជា សីលធម៌ ការសិក្សា .ការអប់រំ ច្បាប់ ទំនៀមទម្លាប់ សិល្ប: អក្សរ ភាសា ជាដើម

ដើម្បីបណ្ដុះខ្លួន មនុស្សម្នាក់ៗ ឲ្យថ្កុំថ្កើងខ្ពង់ខ្ពស់ ៗ

មែកធាងនៃវប្បធម៌

វប្បធម៌ អាចមានមែកធាង ច្រើនថែមយ៉ាងទៅតាម ទស្សនៈផ្សេង ៗ ក្នុងទីនេះ មែកធាងវប្បធម៌ អាចចែកចេញជា :

- **វប្បធម៌**
  - ១–ចំណេះចេះដឹង
    - ជំនឿ Croyance
    - សីលធម៌ Morale
    - សាសនា Religion
    - វិទ្យាសាស្ត្រ Sciences
  - ២– ការផ្សាយ
    - សិល្បៈ-អក្សរសិល្ប៍ Art-Littérature
    - អក្សរសាស្ត្រ Lettres
    - អក្សរ - ភាសា Ecriture-Langı
    - ពត៌មាន Information
  - ៣- ការអនុវត្តន៍
    - ទំនៀមទម្លាប់-ប្រពៃណី Mœur Coutume
    - ការសិក្សា Enseignement
    - ការអប់រំ Education
    - ច្បាប់ Droit

# អរិយធម៌

## Civilisation

### អត្ថន័យ

អរិយធម៌ មានន័យច្រើនបែបយ៉ាង តាមទស្សនៈ អ្នកប្រាជ្ញជាច្រើនរូប ដែលបានគិតគូរសិក្សាពិចារណាអំពីរឿងនេះ ។

– ទស្សនៈខ្លះ យល់ថា: អរិយធម៌គឺធម៌នាំឲ្យកើតសេចក្តីសុខចំរើន ឬអរិយធម៌ គឺបែបបទសណ្តាប់ធ្នាប់របៀបរៀបរយល្អត្រឹមត្រូវ ។ (តាមវចនានុក្រមខ្មែរភាគ២) ។

– ទស្សនៈខ្លះ យល់ថា: អរិយធម៌ គឺរបៀបរបបផ្សេងៗនៃការរីកចំរើន ផុះផាលខាងសតិបញ្ញា ចំណេះចេះដឹង សីលធម៌ ឧស្សាហកម្ម នៃសង្គមមនុស្ស (Larousse XXè siècle) ។

តាមន័យខាងលើនេះ អរិយធម៌ សំគាល់នូវគំនិតដែល

កើតមានឡើង ជាមួយនឹងច្បាប់ផ្សេងៗរបស់មនុស្សដែល រួមរស់នៅជាក្រុម ជាពួក ជាបក្ស ជាសង្គម ហើយដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ មនុស្សដែលរួបរួមគ្នាជាសង្គម រួមរស់នៅស្របស្រួលសុខសប្បាយ ដោយសារមានច្បាប់ជាគោល ជាមូលដ្ឋាន ដែលរៀបចំមនុស្ស សង្គមមនុស្ស ឱ្យមានយុត្តិធម៌ មានចិត្តគំនិតថ្លៃថ្នូរ មានឋានៈខ្ពង់ខ្ពស់ជានិច្ច ហើយមានសមត្ថភាពការពារប្រពៃណីជាតិ យកមកប្រើប្រាស់ជាការចាំបាច់ក្នុងជីវភាពរាល់ថ្ងៃ ។

ដូច្នេះ អរិយធម៌ គឺជាការសម្រេចឡើងខាងវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ និតិសាស្ត្រ ប្រាជ្ញាស្មារតី និងវិស័យវប្បធម៌ ។

-លោកកាលម៉ាក(Karl Marx, 1818 - 1883;ទស្សនវិទូនិងសេដ្ឋកិច្ចវិទូសង្គមនិយមអាល្លឺម៉ង់) យល់ថា: អរិយធម៌ គឺជាតម្លៃខាងសម្ភារៈ ។

—លោកវ៉ែប៊ែរ (Weber 1864-1920, សេដ្ឋកិច្ចវិទូនិងសង្គមវិទូ អាល្លឺម៉ង់) យល់ថា: អរិយធម៌គឺជាកម្រិតនៃវិជ្ជាតិកនិក វិជ្ជាអនុវត្ត គោលច្បាប់ ដែលជាមធ្យោបាយទប់ទល់នឹងធម្មជាតិ ។

—លោកឡាឡង់ ( Lalande , 1732-1807, តារាវិទូបារាំង) យល់ថា: អរិយធម៌ គឺជាកម្រិតមែកធាងច្រើនបែបយ៉ាងក្នុងសង្គមមនុស្សដែលមានលក្ខណៈជាសិល្បៈសាសនា សីលធម៌ វិទ្យាសាស្ត្រ តិកនិកអាចមានជីវិតបន្តគ្នា ក្នុងកាលអាកាស ។

តាមទស្សនៈនេះ អរិយធម៌ គឺជាពន្លឺតំណាងការរស់នៅនៃជនជាតិនីមួយៗ ផ្នែកវប្បធម៌ សង្គមធម៌ ប្រដាប់ប្រើប្រាស់ កិច្ចការ ការងារជាដើម ដែលអាចឲ្យប្រជាជាតិរស់នៅបានសុខស្រួល សម្បូណ៌សប្បាយ មានសន្តិសុខប្រាសចាកទុក្ខភ័យ និងមានវឌ្ឍនភាព ។

—លោកមីរ៉ាបូ (Mirabeau, 1716-1789, សេដ្ឋកិច្ចវិទូបារាំង) យល់ថា : អរិយធម៌ គឺការចំរើនលូតលាស់នៃជនជាតិណាមួយ ដែលជួយទឹងសភាពព្រៃផ្សៃ ។

ទស្សនៈនេះ ឲ្យតម្លៃទៅលើការចំរើនលូតលាស់ខាងវិស័យវិទ្យាសាស្ត្រ តិកនិក របៀបរៀបចំប្រទេសមានច្បាប់ទម្លាប់ត្រឹមត្រូវ នៃប្រទេសណាមួយ ។ ប្រទេសណាមានការរៀបចំអង្គការចាត់ចែងប្រទេស ឲ្យបានថ្កុំថ្កើង ចំរុងចំរើន មានយុត្តិធម៌ក្នុងសង្គម មានសន្តិសុខ គេចាត់ទុកថា ជាអរិយ-ប្រទេស ក្នុងលោក ។

៦ អរិយធម៌ < អរិយ + ធម៌

អរិយ : **Ariya** : ល្អ ប្រសើរ ខ្ពង់ខ្ពស់ ថ្លៃថ្នូរ ឧត្តុង្គ ឧត្តម ។

ធម៌ : **Dharma** : ទ្រឹស្ដី, ធម៌ភាពនាំឆ្ពោះទៅរកវឌ្ឍនភាព និង ការអនុវត្តន៍យ៉ាង

សុខុម ។

ហេតុនេះ អរិយធម៌ គឺទ្រព្យ ធម៌ភាពទាំងឡាយនៃ វឌ្ឍនភាពដែលជាសុភាព រឺជាតម្លៃនៃការរីកចំរើនល្អគួរណាស់ ផុះផាល ល្អប្រសើរ ថ្កើងថ្កើន ខ្ពង់ខ្ពស់ក្នុងជីវភាព សង្គមមនុស្ស ដែលមានរបៀបរបបល្អ មានគ្រឿងប្រដាប់ប្រើប្រាស់គ្រប់ គ្រាន់ ក្នុងគោលបំណងស្វែងរកសេចក្តីសុខ ។

ផ្នែកធំនៃអរិយធម៌:

ផ្នែកដ៏សំខាន់នៃអរិយធម៌គឺ :

- វប្បធម៌
- សង្គមធម៌

ផ្នែកនៃអរិយធម៌ អាចចែកចេញជាច្រើន បែប យ៉ាង ទៅតាមទស្សនៈអ្នកប្រាជ្ញផ្សេងៗ ។ តែក្នុងទីនេះ ផ្នែកនៃអរិយធម៌ អាចចែកជា :

- អរិយធម៌
  - ១- វប្បធម៌
    - 1- ចំណេះចេះដឹង
    - 2- ការផ្សាយ
    - 3- ការអនុវត្តន៍
  - ២- សង្គមធម៌
    - 1- សង្គមសម្ភារៈ
    - 2- សង្គមវិធី
    - 3- សង្គមកេត

# តារាងបង្ហាញមែកធាងអរិយធម៌

១– វប្បធម៌

- ក– ចំណេះចេះដឹង Connaissance
  - 1– ជំនឿ Croyance
  - 2– សីលធម៌ Morale
  - 3– សាសនា Religion
  - 4– វិទ្យាសាស្ត្រ Sciences
- ខ– ការផ្សាយ Information
  - 1– សិល្បៈ + អក្សរសិល្ប៍ Art + Littérature
  - 2– អក្សរសាស្ត្រ Lettres
  - 3– អក្សរ + ភាសា Ecriture + Langue
  - 4– ពត៌មាន Information
- គ– អនុវត្តន៍ Application
  - 1– ទំនៀមទម្លាប់ - ប្រពៃណី Mœur + Coutume
  - 2– ការសិក្សា Enseignement
  - 3– ការអប់រំ Education
  - 4– ច្បាប់ផ្សេងៗ Lois et Droit

- ២- សង្គមធម៌
  - ក- សង្គមសម្ភារៈ
    - 1- ឧបករណ៍សង្គម Matériels sociaux
    - 2- វិធីតិកនិក Technique
    - 3- វិជ្ជាជីវៈ Profession
  - ខ- សង្គមវិធី
    - 1- សេដ្ឋកិច្ច (កសិកម្ម-ឧស្សាហកម្ម-ពាណិជ្ជកម្ម)
    - 2- សង្គមកិច្ច (សន្តិសុខ-សុខភាព-ការងារ)
    - 3- នយោបាយ (ក្នុងប្រទេស-ក្រៅប្រទេស)
  - គ- សង្គមភេទ
    - 1- ឋានៈសង្គម Classes sociales
    - 2- ស្ថាប័ន Institution
    - 3- រដ្ឋ-ប្រជាជាតិ Etat-Nation

វប្បធម៌ + សង្គមធម៌ > អរិយធម៌

# ឥទ្ធិពលអរិយធម៌

ឥទ្ធិពលអរិយធម៌ គឺកម្លាំងអរិយធម៌ ដែលមានកំណក់កំណើត ឬ ប្រភពចេញមកអំពីភូមិមួយ ហើយដែលអាចរុញច្រាន អរិយធម៌ ឲ្យបានខ្ពង់ខ្ពស់ លូតលាស់ចំរើន ។

- ទស្សនៈខ្លះនិយមថា ឥទ្ធិពលអរិយធម៌ ឋិតនៅក្នុងវប្បធម៌ មានប្រភពកើតចេញមកអំពីវប្បធម៌ ។

ទស្សនៈនេះ បានអះអាងថា បំណេះចេះដឹង វិជ្ជា ភាសា អក្សរសិល្បៈ ការសិក្សា ការអប់រំ ទាំងនេះ គឺជាឥទ្ធិពលអរិយធម៌ ដែលអាចកែប្រែផ្លាស់ប្តូរសង្គមមនុស្ស ឲ្យមានគំនិតជីវភាពខ្ពង់ខ្ពស់ មានចរិយាមារយាទថ្លៃថ្នូរ មានរបៀបរស់នៅល្អប្រសើរ មានបញ្ញាប់ទម្លាប់ របៀបគ្រប់-គ្រងរដ្ឋត្រឹមត្រូវ មានយុត្តិធម៌ក្នុងសង្គម មានសន្តិសុខ ។

- ទស្សនៈខ្លះ និយមថាៈ ឥទ្ធិពលអរិយធម៌ឋិតនៅក្នុងសង្គមធម៌ មានប្រភពកើតចេញមកអំពីសង្គមធម៌ ។

ទស្សនៈនេះបានអះអាងថា : សង្គមសម្ភារៈ វិធីរៀបចំសង្គមទាំងនេះជាឥទ្ធិពលអរិយធម៌ដែលអាចកែប្រែផ្លាស់ប្តូរ គំរិតជីវភាព របៀបរស់នៅ ចិត្ត គំនិត យោបល់ ទស្សនៈ ចំណង់ចំណូលចិត្តរបស់បុគ្គលមួយរូប ៗ ឬរបស់សង្គម ឲ្យបានខ្ពង់ខ្ពស់ ល្អប្រសើរ ហើយរៀបចំប្រដាប់ប្រដាប្រើប្រាស់គ្រប់បែបយ៉ាងឲ្យមានគ្រប់គ្រាន់ ចាត់ចែងវិធីបង្កើតផល វិធីចែកចាយផលិតផលជាដើមក្នុងសង្គម ឲ្យបានត្រឹមត្រូវល្អ ប្រកបដោយគតិយុត្តិធម៌ ៗ ព្រមជាមួយនេះ សង្គមធម៌បង្កើតឲ្យមានច្បាប់គ្រប់គ្រងត្រឹមត្រូវល្អ រៀបចំសង្គមតាមមនោសាស្ត្រជាតិ មានការកែប្រែរបបសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ កម្រើរទៅតាមទំនោរ ចំណង់ចំណូលចិត្ត និង ការស្របស្រួលនៃសង្គមមនុស្ស ។

អាស្រ័យហេតុនេះ យើងឃើញថា: ទស្សនៈទាំងពីរនេះ វប្បធម៌និយមក្តី សង្គមធម៌និយមក្តី មានលក្ខណៈ សម្ខុះ ពុំ

សមខ្លះ ត្រូវខ្លះ ខុសខ្លះ ព្រោះឥទ្ធិពលអរិយធម៌មិនបិតនៅក្នុង វប្បធម៌ក៏មាន ក្នុងអរិយធម៌ក៏មាន ។

យ៉ាងណាមិញ :

ដូចកាលជីវភាពក្រីក្រតោកយ៉ាក លំបាកពេកខ្វះមុខខ្វះក្រោយ អាចជំរុញមនុស្សឲ្យមានជំនឿផ្តេសផ្តាសពុំសមហេតុផលខ្វះវិចារណញ្ញាណ ។ ជម្ងឺឈឺកុំរ៉ៃ កើតព្យាធិជានិច្ចកាល សម្រេកឃ្លានអំណត់បាយ ក្រហាយទឹកក៏ជាមូលហេតុណែនាំជំរុញមនុស្ស ឲ្យស្វះស្វែងរកវិធីគេព្យាបាយដោះស្រាយ ដោយពឹងពាក់លើសាសនាឬមានជំនឿផ្តេសផ្តាសផ្តេកផ្តួលលើខ្មោចព្រាយ បិសាច អារក្ស អ្នកតា បង់បត់ មេមត់ ទេវៈ ទេវតា ឥន្ទ្រព្រហ្ម យម យក្ស អាទិទេព ជាដើម សុំឲ្យជួយដោះទុក្ខខ្លួន ។

ដូចកាល សង្គមសម្បូណ៌សប្បាយ ចំរើនរុងរឿងមានសម្ភារៈគ្រប់គ្រាន់ មានថ្នាំកែរោគគ្រប់មុខ មានកំរិតជីវភាព

ខ្ពង់ខ្ពស់ មានសន្តិសុខ សុខភាពបរិបូណ៌ មានយុត្តិធម៌ ក្នុងសង្គមជាដើម ក៏ការបំបាត់វិធីសាសនា និងជំនឿ ផ្តេសផ្តាស បានដោយងាយ ។

ផ្ទុយទៅវិញ ជួនកាលជំនឿនោះមុតមាំងពេកលើទេវៈ កាទិទេព សម្រាប់ប្រើវិធីសាសនា យូរយារក៏អាចមាន ឥទ្ធិពលលើសង្គមមនុស្ស ដោយកាប់មនុស្ស បង្អាត់ បង្រៀនមនុស្ស សម្រាប់មនុស្សឲ្យសុខចិត្តទទួលជីវភាព តាមការក្រខ្សត់ក្រីក្រលំបាកវេទនា ដោយគ្មានត្អូញត្អែរ ឬ រអ៊ូរទាំឡើយ ព្រមទាំងអាចធ្វើឲ្យមនុស្សព្រាសចាកការ តស៊ូនឹងកម្លាំងធម្មជាតិ ក៏មាន ដោយគេយល់ថា ចាំបាច់ កែប្រែខ្លួនធម្មជាតិធ្វើអ្វី បើនៅក្នុងលោកនេះ ធម្មជាតិកើត កាលមកស្រាប់រួចទៅហើយ ហើយសុខតែជាទុក្ខលំបាកថែម ទៀត ។

ត្រង់នេះ គឺជាកម្លាំងវប្បធម៌ ដែលបានគប់មនុស្ស

សង្គមមនុស្ស ឲ្យទទួលយល់ព្រមតាមយថាកម្ម ៗ ប៉ុន្តែទុកណាជាហេតុនេះក៏ដោយ ក៏វប្បធម៌ពុំមែនជាកម្លាំងដាច់ខាតតែម្នាក់ឯង អាចទប់ទល់ ឬ កែប្រែសង្គមមនុស្សបានទាំងអស់នោះទេ គឺចាំបាច់ត្រូវតែមានទំនាក់ទំនងនឹងសង្គមធម៌ផងដែរ ទើបអាចកែប្រែរៀបចំសង្គម ឲ្យមានវឌ្ឍនភាពគ្រប់គ្រាន់ ប្រកបដោយថាមពល និងប្រសិទ្ធភាព ព្រោះវប្បធម៌និងសង្គមធម៌ត្រូវការស្របគ្នា ទាក់ទងគ្នាជាកម្រងបង្កបជានាមនិរូប ៗ

ដើម្បីមើលឲ្យឃើញច្បាស់នូវទំនាក់ទំនងនេះ គេត្រូវមានទស្សនៈ បដិយោគ ដែលអាចនាំឲ្យយើងមើលឃើញ យល់ ស្គាល់ ដឹង នូវសច្ចៈ គឺបរភាពនៃវប្បធម៌និងសង្គមធម៌ ដែលជាធម៌ម៉ែ ៗ បានសេចក្តីថា ផលិតផលអភិយធម៌ គឺជាទំនាក់ទំនង រវាងមនោសាស្ត្រ និងសង្គមសាស្ត្រ ដែលទាំងពីរនេះ កើតលេចចេញមកអំពី

ទំនាក់ទំនងរវាងវប្បធម៌និងសង្គមធម៌ អាស្រ័យគ្នា បងគ្នា ជាផលរួម គឺថា វប្បធម៌ មានឥទ្ធិពល អាស្រ័យលើ សង្គមធម៌ជួយទ្រទ្រង់ ហើយសង្គមធម៌មានកម្លាំងពលំ ក៏ អាស្រ័យលើវប្បធម៌ ជាថ្នាលជាទំរ ជួយទ្រទ្រង់ សង្គមធម៌ នេះឯង ។

ដូច្នេះ ឥទ្ធិពលអរិយធម៌ មានប្រភពកើតចេញមកអំពី ទំនាក់ទំនង រវាងវប្បធម៌ និងសង្គមធម៌ ដែលបានចង ភ្ជាប់គ្នា ជាកម្រង ជាបាច់ ជួយទ្រ រុញច្រានគ្នា ទៅ វិញទៅមក ដើម្បីស្ទួយលើកតំកើង អរិយធម៌ ឲ្យខ្ពង់ ខ្ពស់រីកដុះដាលក្នុងគោលបំណងស្វែងរកសុខៈ ផ្តល់ឲ្យ មនុស្ស សង្គមមនុស្ស ។

* *

*

# ទស្សនៈអ្នកប្រាជ្ញបរទេស

## ចំពោះអរិយធម៌ខ្មែរ

ដោយហេតុថា អរិយធម៌ខ្មែរ មានទំនាក់ទំនងនឹងបរទេស បានទទួលឥទ្ធិពលបរទេសខ្លះ មាន : ឥណ្ឌា ចាម ជ្វា សៀម លាវ ចិន យួន អឺរ៉ុប ជាដើម ទើបមានអ្នកប្រាជ្ញបរទេសខ្លះ បានបញ្ចេញទស្សនៈផ្សេងៗគ្នាអំពីលក្ខណៈអរិយធម៌ខ្មែរ ។

### ១- ទស្សនៈ លោក Cœdès

មានអ្នកប្រាជ្ញជាច្រើនរូបមានលោកសឺដែស ( Cœdès ) ជាតិបារាំង ជាតំណាង បានបញ្ចេញទស្សនៈថា :

អរិយធម៌ខ្មែរ គ្មានលក្ខណៈពិសេសទេ ព្រោះខ្មែរ បានទទួលឥទ្ធិពលមកអំពីបរទេសទាំងអស់ ។

លោកសឺដែស បានបង្រួមទស្សនៈបែបនេះ គឺការ

វិនិច្ឆ័យថា: «ខ្មែរ គឺជាភ្នង ស៊ីវិល័យដោយសារឥណ្ឌា» (Les khmers sont des Phnong hindouisés) ក្នុងសៀវភៅឈ្មោះ Les Etats hindouisés ។

អាស្រ័យរឿងនេះហើយ បានជាអ្នកប្រាជ្ញបរទេសខ្លះ ពុំទទួលស្គាល់ប្រទេសខ្មែរ ថាជាប្រទេសមានឈ្មោះជាខ្មែរទេ តែជារដ្ឋស៊ីវិល័យតាមឥណ្ឌា ពោលគឺ ជារដ្ឋក្រោមឥទ្ធិពលឥណ្ឌា ព្រោះគេយល់ថា ប្រទេសទាំងឡាយនៅអាស៊ី មានខ្មែរជាដើម កាលដំបូង មានមនុស្ស មានសាសនា មានរបៀបរស់នៅ មានទំនៀមទម្លាប់ មានការចេះដឹង ដោយសារតែឥទ្ធិពលឥណ្ឌា ។

គេផ្ដើមប្រវត្តិសាស្ត្រខ្មែរ ក្នុងសម័យក្សត្រឥណ្ឌាមួយរូប ឈ្មោះកៅណ្ឌិន្យ ឬ ហ៊ុនទៀន ដែលបានមកគ្រប់គ្រងគ្រងគ្រា ប្រទេសខ្មែរ ។ ទុកណាជារឿងនេះ គ្រាន់តែជារឿងដំណាល ដោយសារអ្នកដំណើរចិនឈ្មោះ ជីវ-

តាក្កាន់ ក៏ដោយ ក៏អ្នកប្រាជ្ញបារាំងខ្លះ នៅតែមានជំនឿមុតមាំ និយមទុករឿងនេះ ជាឯកសារសំខាន់បំផុត ដែលអាចប្រាប់បង្ហាញថា ខ្មែរមានប្រភពមកអំពីឥណ្ឌា ។ ព្រមជាមួយនេះ គេក៏បានលើកយកហេតុភេទច្រើនយ៉ាងទៀត ក្នុងផ្នែកខាងវប្បធម៌មាន អក្សរ ភាសា សិល្បៈ សាសនា ជំនឿ ទំនៀមទម្លាប់ជាដើម ទុកជាភស្តុតាងបញ្ជាក់ថា ខ្មែរមានអរិយធម៌ចេញមកអំពីបរទេស ថែមទៀត ។

ក្រៅអំពីនេះ មានអ្នកប្រាជ្ញខ្លះទៀត បានសង្កត់យ៉ាងខ្លាំងលើលក្ខណៈបរទេស នៃអរិយធម៌ខ្មែរ ដែលមានទំនាក់ទំនងនឹងប្រទេសជិតខាងមាន: ចាម ជ្វា សៀម លាវ ចិន យួន ជាដើម ។ ពិសេស សព្វថ្ងៃនេះ មានទស្សនៈយល់ថា អរិយធម៌ខ្មែរចំរើនលូតលាស់ដុះដាលបាន ដោយសារតែអរិយធម៌អ៊ឺរ៉ុប ។ ប៉ុន្តែ ទស្សនៈខ្លាំងជាងគេ ដែលបានសំអាងទៅលើហេតុផលផ្សេងៗ ហើយ

ទំនាញបញ្ចេញខ្មែរ អំពីវណ្ណាគឺជាទស្សនៈ ដែលផ្តុកផ្តួល សំអាងទៅលើ :

- ផ្នែកប្រវត្តិសាស្ត្រ Histoire
- ផ្នែកភាសា Langue
- ផ្នែកអក្សរ Ecriture
- ផ្នែកសិល្បៈ Art
- ផ្នែកសាសនា Religion ជាដើម ។

### ផ្នែកប្រវត្តិសាស្ត្រ– **Histoire**

រឿងស្ដេច កៅណ្ឌិន្យ ឬ ហ៊ុនទៀន ដែលបាន បេញមកអំពីប្រទេសឥណ្ឌាភាគខាងកើត ចូលមកបង្ក្រាំងឈ្នះ មេទ័ពស្រីខ្មែរឈ្មោះសោមា ឬលីវយី ហើយក៏បានគ្រប់គ្រងត្រួតត្រា ប្រទេសខ្មែរ សម័យនគរភ្នំ (ហ្វូណន) ប្រហែលសតវត្សរ៍ទី ១ ឬទី ២ នៃ គ.ស (តាមឯកសារផ្នែក ដំណើរចិន ឈ្មោះ ជីវ-តា-ក្វាន់) ។

ផ្នែកភាសា— **Langue**

ក្នុងភាសាខ្មែរ មានលាយចម្រុះដោយពាក្យបាលី សំស្ក្រឹតយ៉ាងច្រើន ប្រើលាយគ្នាជាមួយភាសាខ្មែរ តាំងតែពីយូរយារណាស់មកហើយ ដូចជាពាក្យថា: អក្សរ សិល្បៈ ភាសា សីល ទាន បុណ្យ បាប មគ្គ ផល គុណ ទោស ហេតុ កេរ្តិ៍ សួគ៌ នរក និព្វាន ជាដើម ។

ផ្នែកអក្សរ— **Ecriture**

គេថា អក្សរខ្មែរ មានប្រភព មានដើមកំណើតចេញមកពីអក្សរឥណ្ឌាខាងទក្ខិណបថ ទម្រង់ព្រហ្មី (**Brahmi**) ព្រោះគេបានឃើញអក្សរសិលាចារឹកខ្មែរ ដែលចាស់ជាងគេនៅវ៉ូកាញខេត្តញ៉ាត្រាង (វៀតណាមកណ្ដាល) មានលំនាំទ្រង់ទ្រាយ ដូចគ្នានឹងអក្សរសិលាចារឹកឥណ្ឌាភាគខាងត្បូង ត្រង់ខ្ពង់រាបដេកង់ (Dekkan) ។

## ផ្នែកសិល្បៈ - **Arts**

ក្នុងសិល្បៈខ្មែរ មានរូបគំនូរចម្លាក់ជាច្រើនណាស់ ដែលគូរឆ្លាក់យកលំនាំតាមសិល្បៈឥណ្ឌា ដូចជារូបព្រះស្រីបុំ ដែលបានមកពីក្រៅប្រទេស គាប់ប្រសើរល្អតល្អន់ និងរូបតំ-ណាងទេវឥណ្ឌា ឬ តំណាងទស្សនៈជំនឿ ក្នុងលទ្ធិព្រាហ្មណ៍ ដូចជា រូបឥសូរ ឬ សិវៈ ( Içvara ou Çiva ) រូបវិស្ណុ ឬ នារាយណ៍ (Visnu ou Nârâyana) រូបព្រហ្ម ( Brahma ) ជាដើម ។ ជាពិសេសសិល្បៈខ្មែរ សម័យអង្គរ បានបង្ហាញរូបចម្លាក់ច្រើនបែបយ៉ាង ដែលមានទំនាក់ទំនងនឹងឥណ្ឌា ហើយនិងលទ្ធិព្រាហ្មណ៍ ដូចជារូបចម្លាក់នៅជុំវិញជញ្ជាំងប្រាសាទអង្គរវត្តជាដើម ដែលបានបង្ហាញអំពីលទ្ធិព្រាហ្មណ៍ មានរឿងរាមាយណៈ និងរឿងមហាភារតយុទ្ធ ( Ràmàyana et Mahabharatayuddha ) ជាដើម ។

## ផ្នែកសាសនា - **Religion**

ប្រវត្តិសាស្ត្រខ្មែរ បានបង្ហាញឲ្យឃើញថា សាសនា

ព្រាហ្មណ៍ ដែលព្រហ្មនិយម សិវនិយម ឬ វិស្ណុនិយម ព្រមទាំងពុទ្ធសាសនា ដែលមហាយាន ឬ ហីនយាន បានប្រភពចេញមកអំពីឥណ្ឌាហូរចូលមកក្នុងប្រទេសខ្មែរ តាំងតែពីយូរយារណាស់មកហើយ ហើយមានជាហូរហែរហូតមកដល់សព្វថ្ងៃនេះ ។

ហេតុទាំងនេះ ជាភស្តុតាងសំខាន់បំផុត ដែលអ្នកប្រាជ្ញបរទេស លើកយកមកធ្វើជាលេស ជាសំអាង ជាមូលហេតុ សំពច់ភ្ជាប់ខ្មែរទៅនឹងឥណ្ឌា ឬ ទាញខ្មែរចេញអំពីឥណ្ឌា ។

| | | |
|---|---|---|
| សាសនាព្រាហ្មណ៍ | – ព្រហ្មនិយម | Brahmanisme |
| | – សិវនិយម | Çivaïsme |
| | – វិស្ណុនិយម | Visnuisme |
| ពុទ្ធសាសនា | – មហាយាន | Grand Véhicule |
| | – ហីនយាន | Petit - Véhicule |

សាសនា មាននៅប្រទេសខ្មែរ ក៏បណ្ដាលឲ្យមានជំនឿផ្សេងៗ : មានជំនឿចំពោះទេវៈ ទេពតា, ជំនឿបុណ្យ បាប គុណ ទោស អាក្រក់ ល្អ ឋានសួគ៌ ឋាននរក ជាដើម មានទំនៀមទម្លាប់ ពិធីបុណ្យទានផ្សេងៗ ព្រមទាំងមានរបៀបរស់នៅខ្លះ ដែលជាផលវិបាកកើតចេញមកអំពីការប្រកាន់ជឿស៊ប់លើសាសនា ដូចជា : តាជី ដូនជី យាយជី លោកពុតគ្គ អ្នកសង្ខំ ជាដើម ។

សាសនា ចេញមកអំពីឥណ្ឌា ជំនឿ ទំនៀមទម្លាប់ របៀបរស់នៅ ក៏ចេញមកអំពីឥណ្ឌាដែរ ។ ខ្មែរបានទទួលសាសនាឥណ្ឌា តាំងតែពីយូរអង្វែងណាស់មកហើយ, សព្វថ្ងៃនេះ សាសនាឥណ្ឌាបានចាក់ឫសយ៉ាងមាំ មុតជាប់យ៉ាងជ្រៅក្នុងចិត្តគំនិតខ្មែរ ទំនោរខ្មែរ សង្គមខ្មែរនិងក្នុងវប្បធម៌ អរិយធម៌ខ្មែរ ។

:អាស្រ័យហេតុកេទផ្សេងៗ ផ្នែកវប្បធម៌ និងសង្គម

ធម៌ ខាងលើនេះហើយ ដែលអ្នកប្រាជ្ញបរទេស បានលើកយកមកធ្វើជាភស្តុតាងជាសំអាងបញ្ជាក់ថា ខ្មែរជាពូជ ស៊ីវិល័យដោយសារឥណ្ឌា ។ មិនតែប៉ុណ្ណោះ ចំពោះជាតិសាសន៍ ( Race des peuples ) ក៏គេថាមកអំពីឥណ្ឌាដែរ ។ យ៉ាងណាមិញ គេថាខ្មែរពុំមែនជាជនជាតិដើមបង្អស់នៅប្រទេសខ្មែរទេ តែជាជនជាតិមានប្រភព មានដើមកំណើតមកអំពីឥណ្ឌាភាគខាងត្បូង ។ ជនជាតិមកអំពីឥណ្ឌានេះ បាននាំយកមកជាមួយនូវភាសា អក្សរ វប្បធម៌ សង្គមធម៌ឥណ្ឌាចូលមកក្នុងប្រទេសខ្មែរ ។

ដូច្នេះ អារ្យធម៌ខ្មែរ គ្មានលក្ខណៈពិសេសផ្ទាល់ខ្លួនទេ គឺសុទ្ធតែទទួលមកអំពីឥណ្ឌាទាំងអស់ ។

## សង្កេត:

ទស្សនៈបែបខាងលើ បានមកយូរយារណាស់ហើយ រហូតដល់បណ្ដាលឲ្យជនជាតិខ្មែរខ្លួនឯង ភាគខ្លះក៏ពុំព្រម

ទទួលស្គាល់ថាជាប្រទេសខ្មែរថែមទៀត តែជាប្រទេសកម្ពុជា ដែលមានប្រភពចេញមកអំពីប្រទេសឥណ្ឌា គ្រង់ភូមិភាគ មួយឈ្មោះកម្ពុជា( Kamboja ) ។ ទម្លាប់ទទួលសារភាពថា ខ្មែរមានប្រភពចេញមកអំពីបរទេសនេះហើយ ដែលឲ្យនាំ ខ្មែរខ្លះ សព្វថ្ងៃនេះ យល់ច្រឡំ ដោយខ្វះការពិចារណា ខ្វះ មនសិការជាតិ·ថា ភាសា អក្សរ សិល្បៈ អក្សរសិល្ប៍ វប្បធម៌ ទំនៀមទម្លាប់ ខ្មែរ គឺសុទ្ធតែដួចឥណ្ឌា ចេញ មកអំពីឥណ្ឌា ទទួលឥទ្ធិពលឥណ្ឌាទាំងអស់ គឺគ្មានអ្វីដែល ជារបស់ខ្មែរសុទ្ធ១ ទេ ។ តើទស្សនៈនេះពិត ឬទេ ?

## ២- ទស្សនៈ លោក Groslier

មានអ្នកប្រាជ្ញជាច្រើនរូបផ្សេងទៀត ដែលមានលោក Groslier ជាតិបារាំង ជាតំណាង បានបញ្ចេញទស្សនៈថាៈ

«ខ្មែរមានអរិយធម៌ពិសេសរបស់ខ្លួន តែជាលទ្ធផល កើតចេញមកអំពីអរិយធម៌ឥណ្ឌា » ។

លោក Groslier បានបញ្ជាក់ បង្ហាញ ពន្យល់គ្រប់ចំណុចណា សេចក្ដីណា ដែលមានទំនាក់ទំនងនឹងឥណ្ឌា ឬដែលមានមកអំពីឥណ្ឌា ។ ដើម្បីបញ្ជាក់ថាខ្មែរបានទទួលយកអរិយធម៌ វប្បធម៌ឥណ្ឌា មកប្រើប៉ុណ្ណោះ លោក Groslier បានចំណុចលើលក្ខណៈ អរិយធម៌ខ្មែរ ផ្នែកចំរើនសង្គម និងអង្គការសេដ្ឋកិច្ច ដែលអាចចែកជាគោលគឺ:

- ទីនិយម
- ឥណ្ឌានិយម

## ១- ទីនិយម

លោក Groslier បានចំអះអាងថា ប្រទេសខ្មែរជាស្រុកតូច មានទឹកនិងវាលស្រែ ដែលទុកជាទីកន្លែងសំរាប់ទទួលយកនូវអរិយធម៌ឥណ្ឌា ។ លោក Groslier បានបញ្ជាក់ថា ទឹកខ្មែរ ដីខ្មែរ ពុំមែនជាមូលហេតុ សំរាប់បង្កើតអរិយធម៌ខ្មែរទេ គឺគ្រាន់តែជាទីកន្លែង ជាថ្នាល សំរាប់

ទទួលយកនូវសំណាប គឺអរិយធម៌ឥណ្ឌាហើយ ដែលឥណ្ឌាបានសាបព្រួសនៅលើដីខ្មែរតែប៉ុណ្ណោះ ។ សារុបទៅ អរិយធម៌ខ្មែរគឺអរិយធម៌ឥណ្ឌា ដុះលូតលាស់លើទីថ្នាលដីខ្មែរ ដោយសារអ្នកឥណ្ឌាសាបព្រួស ។

## ២-ឥណ្ឌានិយម

លោក Groslier បានឲ្យតម្លៃលើមូលហេតុសំខាន់ៗនៃកំណកំណើតអរិយធម៌ខ្មែរ គឺឥណ្ឌា ។

អរិយធម៌ឥណ្ឌា បានចូលមកក្នុងប្រទេសខ្មែរតាមដំណើរនាំចូលនៃអ្នកឥណ្ឌា ពីរពួកសំខាន់គឺ:

១- ពាណិជ្ជ : ពួកឈ្មួញឥណ្ឌាតែងតែធ្វើដំណើរឆ្លងកាត់ភូមិភាគផ្សេងៗ តាមសំពៅអស់កាលជាយូរ ដែលជាហេតុនាំឲ្យគេត្រូវឈប់សំចត តាមភូមិភាគនិងប្រទេសនានានៅក្បែរសមុទ្រ មានជ្រោយឥណ្ឌូចិនជាដើម ពិសេសប្រទេសខ្មែរ ដែលមានកំពង់ផែមួយដ៏សំខាន់គឺ កំពង់ផែ

ស្បែក ៗ អ្នកជំនួញឥណ្ឌា ត្រូវការលក់ដូរវត្ថុផ្សេងៗ មាន កំណាត់សំពត់ជាដើមឲ្យខ្មែរ តែឈ្មួញឥណ្ឌា ត្រូវការទិញ អំពីខ្មែរវិញនូវ ម្រេច ដីប៉ូ ផ្កា ជាដើម ៗ ម្ល៉ោះ ហើយឈ្មួញឥណ្ឌា ត្រូវឈប់សំចតយូរក្នុងប្រទេសខ្មែរ ៗ កាលបើយ៉ាងនេះ ឈ្មួញឥណ្ឌាចាំបាច់ ត្រូវតែមានទំនាក់ ទំនងនឹងអ្នកស្រុកតាមរបៀបរស់នៅខ្លះ តាមទំនៀមទម្លាប់ ខ្លះ នៃសង្គមខ្មែរ ៗ កាលបើនៅស្រុកខ្មែរយូរ គេក៏មាន ករណីយកិច្ចចាំបាច់ត្រូវតែផ្សាយសាបព្រោះ បណ្តុះ វប្បធម៌ អរិយធម៌គេផង ដូចជាសាសនា ជំនឿ ទេវៈ មន្តគាថា អូមអាម ទំនៀមទម្លាប់ ជាដើម ៗ

២~ តាមអ្នកមានអំណាច.— ពួកឥណ្ឌាខ្លះទៀត ដូចជាកៅណ្ឌិន្យ ឬ ហ៊ុនទៀន ជាអ្នកមានអំណាច បានលើកគ្នាជិះសំពៅមកច្បាំងឈ្នះមេទ័ពស្រីខ្មែរឈ្មោះ សោមា ឬ លិវយី ហើយបានគ្រប់គ្រងត្រួតត្រាប្រទេសខ្មែរ សម័

នគរភ្នំ (ហ្វូណន) កាលសតវត្សទី ១ ឬ ទី ២ នៃ គ.ស ។ ម្ល៉ោះហើយ គេចាំបាច់ត្រូវតែយកភាសា អក្សរ សិល្បៈ ជំនឿ សាសនា ប្រពៃណី ទំនៀមទំលាប់របស់គេ មកប្រើ មកអនុវត្ត នៅប្រទេសខ្មែរ រហូតដល់បានក្លាយទៅជាអរិយធម៌ខ្មែរ ។

ឥណ្ឌាបាននាំមកឲ្យខ្មែរនូវ :

1– វិធីគិតគូរកសាងធ្វើទំនប់ទឹក-ប្រឡាយទឹក

2– ជំនឿ សាសនា មន្តអាគម

3– របៀបគ្រប់គ្រង រៀបចំស្រុកទេស

4– អក្សរ ភាសា បាលីសំស្ក្រឹត ។ល។

លោក Groslier បានចំបញ្ជាក់ ពន្យល់ថា ធាតុទាំង ២ គឺផ្នែកអរិយធម៌ ដែលឥណ្ឌានាំចូលមក បំផុតជាសំណាប ដែលត្រូវយកមកស្ទូងបញ្ចាំនៅលើដីខ្មែរ ដីខ្មែរដែលអាចស្រូបស្រួលទទួលយកបាន ។

ហេតុនេះ យើងឃើញថា ទស្សនៈនេះ ជាទស្សនៈ ឥណ្ឌានិយម ដែលបានពន្យល់បង្ហាញឲ្យឃើញថា អ្វីៗ ដែលមាននៅក្នុងអរិយធម៌ខ្មែរ ពោលគឺ ទំបង្ហាញធាតុពិសេសនៃឥណ្ឌា ដែលបង្កើតឲ្យបានជាអរិយធម៌ខ្មែរ ។

ដូច្នេះ តាមទស្សនៈអ្នកប្រាជ្ញបរទេស យើងឃើញថា:

-" ខ្មែរជាពួក ស៊ីវិល័យ ដោយសារឥណ្ឌា "

(G. Coedès)

-" ខ្មែរគ្មានអរិយធម៌ពិសេសរបស់ខ្លួនឯង តែជាលទ្ធផលកើតចេញមកអំពីអរិយធម៌ឥណ្ឌា "( Groslier )

ហេតុនេះ តើអរិយធម៌ខ្មែរមានលក្ខណៈពិសេសផ្ទាល់ខ្លួនឬទេ ?

ក្នុងអរិយធម៌ជនជាតិណាក៏ដោយ តែងតែមានធាតុសំខាន់ ២ យ៉ាង ដែលជាចំនាក់ចំនង់ឬជាចំនាស់ទៅវិញទៅមកគឺ :

១- មូលធាតុ ជាតិ

២- មូលធាតុ បរទេស ។

អរិយធម៌បរទេស ដែលអាចផ្សាយចូលទៅក្នុងប្រទេសណាមួយបាន លុះត្រាតែមូលដ្ឋានជាតិដែលជាជាតិសាសន៍ អ្នកស្រុក មានភាសា ជីវភាព ខាងរបៀបរស់នៅ ទំនៀមទម្លាប់ ឬ ចំណេះវិជ្ជាបែបណាមួយ ស្របស្រួលទៅហើយ ។ មូលដ្ឋានជាតិជាទីទួលនិងជាទីពិសេស សំរាប់ទទួលធាតុបរទេសគឺ អរិយធម៌បរទេស ។

ម្យ៉ាងទៀត ក្នុងការជួបប្រទះរវាងជាតិ និងបរទេស, ទំនាក់ទំនងអាចមានដំណើរលក្ខណៈច្រើនបែបយ៉ាងគឺ:

- ជាការស្របស្រួល ចុះសម្រុងគ្នា
- ជាការប្រយុទ្ធប្រឆាំង សង្កត់សង្កិនគ្នា
- ឬជាទំនាស់វិបត្តិ

ឬជាការសុខចិត្តយល់ព្រមទទួលយក ដោយត្រង់ៗ

ទាំងស្រុង ឬដោយការចម្លងកែសម្រួល ឲ្យមានលក្ខណៈជាតិពិតៗ ។

រីឯ អរិយធម៌ខ្មែរវិញ ក៏ឋិតនៅលើមូលធាតុសំខាន់ទាំង ២ យ៉ាងនោះដែរគឺ:

១~ មូលធាតុជាតិ : ខ្មែរ មានប្រទេស មានមនុស្សរស់នៅ ជាយូរអង្វែងមកហើយ តាំងតែពីមុនឥណ្ឌាចូលមកម៉្លេះ ។ បានសេចក្ដីថា ខ្មែរមានភាសា មានរបៀបរស់នៅ និងចំណេះវិជ្ជា មានជាតិសាសន៍ មានការរៀបចំស្រុកទេស តាំងតែពីយូរយាររួចស្រេចហើយ មុនការនាំចូលអរិយធម៌ឥណ្ឌា ។

២~ មូលធាតុបរទេស : អរិយធម៌ឥណ្ឌា បានចូលមកក្នុងអរិយធម៌ខ្មែរ គ្រាន់តែជាជំនួយ ជួយបំពេញគន្លងខាតខ្លះ និងកំណែទម្រង់ខ្លះតែប៉ុណ្ណោះដូចជា : ពុទ្ធសាសនា, ពាក្យសំដី, ភាសាបាលី សំស្ក្រឹត, សិល្បៈបុរាណខ្លះ ជាដើម

តែប៉ុណ្ណោះ ៗ បានសេចក្ដីថា អរិយធម៌ឥណ្ឌា គ្រាន់តែជាធាតុ ១ ដែលបានចូលមករួបរួម ក្នុងដំណើរកកើតនិងការផ្លាស់ប្ដូរ នៃអរិយធម៌ខ្មែរ ដែលមានរូបស្រេចមកហើយ តែពុំទាន់សព្វគ្រប់ ៗ អរិយធម៌ឥណ្ឌា បំណុចខ្លះស្របស្រួលនឹងខ្មែរក៏អាចរស់ពនមានជីវិតនៅយូរបាន ៗ ឯបំណុចខ្លះទៀត ដែលមិនស្របស្រួល មិនមានទំនាក់ទំនងនឹងមនោសាស្ត្រខ្មែរ ក៏ត្រូវរលុបរលាយបាត់បង់ទៅវិញ ៗ យ៉ាងណាមិញ :

អរិយធម៌ខ្មែរ មានលក្ខណៈពិសេសមួយផ្ទាល់ គឺមូលធាតុជាតិ ដែលជាទំនោរចិត្ត គំនិត ព្រលឹង មនោគមន៍ខ្មែរពិត ៗ ៗ

*

* *

# មូលធម៌នៃវប្បធម៌ អរិយធម៌ឥណ្ឌា ក្នុងវប្បធម៌ អរិយធម៌ខ្មែរ

ធាតុសំខាន់ៗ នៃវប្បធម៌ អរិយធម៌ឥណ្ឌាដែលបាន ជាក់ឫសយ៉ាងមាំហើយជាកត្តាដ៏សំខាន់ជួយទ្រទ្រង់ វប្បធម៌ អរិយធម៌ ខ្មែរ អាចកប់ជាគោលគឺ :

១– សាសនាព្រាហ្មណ៍ ឬ លទ្ធិព្រាហ្មណ៍ :

– វេទនិយម

– ព្រាហ្មណ៍និយម

២– ពុទ្ធសាសនា ឬ ពុទ្ធិលទ្ធិ :

– ព្រះត្រៃបិដក

– បញ្ហាកម្មផល - បុណ្យបាប

* *

*

# វេទនិយម

## Vedisme

វេទនិយម គឺជាឈ្មោះលទ្ធិបូរាណមួយ មាននៅក្នុងប្រទេសឥណ្ឌា ហើយដែលបាននិយមឲ្យតម្លៃទៅលើវេទ (គម្ពីរវេទ) ដោយភ្ជាប់មនុស្សទៅនឹងលោកៈ - ទេវៈ ។

វេទ **Veda:** .— គឺជាពុទ្ធិពិសិដ្ឋ (Connaissance sacrée) ឬជាពុទ្ធិដ៏ស័ក្តិសិទ្ធិ ដែលជាអំណោយអាទិទេព ។

អាទិទេព បានប្រគល់គម្ពីរវេទឲ្យមនុ (Manu) ដែលជាមនុស្សបឋមបំផុតគេក្នុងលោក ។ មនុ បានផ្សាយគម្ពីរវេទដល់ពួកឫសិ (Rṣi = Ascète = ឥសី) តាមស្រុតិ (Sṛti = Revélation) ។ ពួកឫសិក៏បានបង្រៀនវេទមន្តមកឲ្យពួកព្រាហ្មណ៍ (Brâhmana) តាមការរៀនតាម យល់តាម សូត្រតាម ដោយពុំមានសិទ្ធិសួរដេញដោលរកខុសត្រូវសោះឡើយ ព្រោះគម្ពីរវេទ ជាអំណោយអាទិទេព

មានលក្ខណៈជាសច្ចៈ ។ ឯពួកព្រាហ្មណ៍ មានសិទ្ធិផ្ដាច់មុខក្នុងការកាន់កាប់សិក្សាផ្សាយគម្ពីរវេទ ។

គម្ពីរវេទ កើតមានឡើងប្រហែលតាំងតែពី ១៥០០ ឆ្នាំមុន គ.ស ។

## ត្រៃវេទ

គម្ពីរវេទមាន ៣ ហៅថា "ត្រៃវេទ = វេទបី" គឺ:

១- ឫគ្វេទ Ṛgevda

២- សាមវេទ Sàmaveda

៣- យជុរវេទ Yajurveda

ក្រោយមក គេបន្ថែមវេទ មួយទៀតជាទី ៤ ហៅថា អថវ៌វេទ Atharvaveda ។

ដូច្នេះ គម្ពីរវេទ មាន ៤ គឺ:

១- គម្ពីរ ឫគ្វេទ ( Ṛgveda ) ជាពាក្យឆន្ទ ពាក្យកាព្យ សម្រាប់សូត្រស្ដុតិសរសើរគោរពទេព និងទេវៈ

ផ្សេងៗ ផង សម្រាប់សូត្រសំបូងសម្រួង បួងសួង អង្វរករ អាទិទេព ៗ ទេវៈ សុំប្រសិទ្ធិពរ ឲ្យបានសម្រេច តាមបំណង ៗ

២– គម្ពីរ សាមវេទ ( Sàmaveda ) ជាពាក្យឆន្ទ ពាក្យកាព្យ សម្រាប់សូត្របន្ទន់ចិត្តទេវៈ អាទិទេព ក្នុង ពេលធ្វើពិធីបូជា ទេវៈ ៗ

៣– គម្ពីរ យជុរវេទ ( Yajurveda ) ជាពាក្យកម្រងកែវ សំម្រាប់សូត្របួងសួង សុំអាទិទេព ទេវៈ ឲ្យចុះមកជួយ ដើម្បីឲ្យមានឫទ្ធិ តេជៈ បារមី មានជោគជ័យ និងជា គម្ពីរ ចែងអំពីការធ្វើពលិកម្ម ៗ

៤– គម្ពីរអថវ៌វេទ ( Atharvaveda ) ជាគម្ពីរ ចែង អំពីមន្តអាគមគាថា អូមអាម ពូកែស័ក្តិសិទ្ធិ សម្រាប់ សូត្របណ្ដេញ បំបាត់ ឧបទ្រព ចង្រៃ ខ្មោច ព្រាយ បិសាច អារក្ស អ្នកតា ធ្មប់ អាប ជាដើម

សម្រាប់សូត្រដាក់ស្នេហ៍ ធ្វើឲ្យគេស្រឡាញ់ ពេញចិត្ត មានសិរីសួស្តី មានស្នេហ៍មុខ ឬ សម្រាប់សូត្រធ្វើឲ្យគេ បំបាត់វេទនា មានទុក្ខ ក្តៅក្រហាយ វិនាស ហិនហោច ជាដើម ។

ប៉ុន្តែ ទោះបីគម្ពីរវេទ មាន ៤ យ៉ាងនេះក៏ដោយ ក៏ គេនៅតែហៅថា "ត្រៃវេទ=វេទបី" ដដែល គឺគេពុំហៅថា ចតុវេទ=វេទ ៤" ទេ ព្រោះ គម្ពីរអថវិវេទ គេបានបន្ថែម នៅពេលក្រោយ ។

ម្យ៉ាងទៀត គម្ពីរវេទនីមួយៗនេះ មានគម្ពីរអដ្ឋកថា មួយៗជាជំនួយពន្យល់ថែមទៀត គឺ:

១- គម្ពីរ ព្រាហ្មណ: ជាគម្ពីរនិយាយពន្យល់អំពីពិធី សក្តិសិទ្ធិ របស់ពួកព្រាហ្មណ៍ ។

២- គម្ពីរ អារណ្យក: "នៅព្រៃ" ជាគម្ពីរ ដែលថែង អំពីការត្រូវរស់នៅក្នុងព្រៃ ឆ្ងាយដាច់អំពីសង្គមមនុស្ស ។

៣- គម្ពីរ ឧបនិស័ទ «នៅជិត» ជាគម្ពីរដែលត្រូវសិក្សា ស្វាធ្យាយ ភ្ជាប់នឹងគម្ពីរព្រាហ្មណៈ និងអារណ្យកៈ ។

អ្នកដែលគោរពជឿទេវៈ អាទិទេព ហើយបានសិក្សារៀនសូត្រ ប្រព្រឹត្ត ប្រតិបត្តិតាមគម្ពីរវេទវមែងត្រូវបានអាទិទេពសង្គ្រោះ ឲ្យរួចពាកទុក្ខទាំងពួង ។ ក្នុងលទ្ធិវេទ មនុស្សសម្លាប់មនុស្សសត្វធ្វើពិធីបូជាយញ្ញ ថ្វាយអាទិទេព ត្រូវបានឈ្មោះថា ជាអ្នកមានភក្តីភាព គោរពបូជា អាទិទេព ហើយត្រូវបានបុណ្យច្រើន ។

## អាទិទេព - Dieu

អាទិទេព គឺជា ទេវៈធំបង្អស់ មុនគេបង្អស់ដែលបានបង្កើតលោក ផងទាំងពួង ។ អាទិទេពមានគុណសម្បត្តិ ដូចតទៅ:

- មហត្ត: សមៀមអស្ចារ្យ
- មហិទ្ធិ ឫទ្ធិ គ្មានគូប្រដូច

- សព្វញ្ញូ ចេះយល់ដឹងសព្វ
- ញាណ ភ្នែកចិត្ត ត្រចៀកចិត្ត
- តេជៈ ឫទ្ធិ បារមី ដ៏ខ្លាំងក្លា
- និមល - គ្មានមន្ទិលសៅហ្មង ។ល។

## បញ្ញាពុទ្ធិ ភាវៈ សុខៈ

**អំពីពុទ្ធិ - La Connaissance .-**

ពុទ្ធិ ដ៏ប្រសើរខ្ពង់ខ្ពស់បរិសុទ្ធគឺពុទ្ធិ ដែលកើតឡើងអំពី អាទិទេព និង អំពីគម្ពីរវេទ ទាំង ៤ គឺ:

- ឫគ្វេទ
- សាមវេទ
- យជុវេទ
- អថរិវេទ

អ្នកដែលមានសិទ្ធិ ទទួលយកនូវពុទ្ធិដ៏បរិសុទ្ធនេះ ពួកព្រាហ្មណ៍ និងពួកក្សត្រ ។

អំពីភាវៈ – **L'être** .-

ភាវៈ ទាំងអស់គឺលោកៈ ធម្មជាតិ ជាដើម សុទ្ធតែកើតឡើងដោយសារ អាទិទេព ។ លោកៈ នេះកើតឡើងដោយសារព្រះឥន្ទ្រ ។ គង់គណើជាអ្នកសាងលោក ព្រះឥន្ទ្របានយកសសរ មកដាំ ហើយយកផ្ទៃមេឃធ្វើជាដំបូល ។

អំពីសុខៈ – **Le Bonheur** .–

សេចក្ដីសុខសប្បាយគ្រប់បែបយ៉ាង ពិតនៅក្នុងកណ្ដាប់ដៃអាទិទេព ដែលជាអ្នកផ្ដល់ឲ្យមនុស្សលោក ។ ដើម្បីបានសេចក្ដីសុខ មនុស្សម្នាក់ៗ ត្រូវមានភក្ដីភាពស្មោះត្រង់ចំពោះអាទិទេព បួងសួងអង្វរករសុំពរទេពដោយធ្វើពិធីបូជាយញ្ញជាដើម ថ្វាយចំពោះអាទិទេព ។

អាស្រ័យហេតុនេះ យើងឃើញថា បញ្ហា ពុទ្ធ ភាវៈ សុខៈ ទាំងអស់នេះ តាមលទ្ធិវេទ គឺសុទ្ធតែកើតឡើងអំពី

អាទិទេព ដោយសារអាទិទេព ៗ ពុះសេចក្ដីថាអាទិទេព ជាអ្នកបង្កើតពុទ្ធិការៈ សុខៈ ៗ

* *

# ព្រាហ្មណ៍និយម

**Brahmanisme**

ព្រាហ្មណ៍និយម ឬ លទ្ធិព្រាហ្មណ៍ កើតមានតាំងតែអំពីសតវត្សទី ៥ មុន គ.ស. ជាងសម្ប្រទះ ទ្រឹស្តី នោះពនិយម តាមពួកព្រាហ្មណ៍ គោរពបូជាទេវៈ អាទិទេព ៗ

អាទិទេព ឬ ទេវៈ ធំៗ ដ៏សំខាន់ ក្នុងលទ្ធិព្រាហ្មណ៍មាន ៣ ហៅថា ត្រីមូត្តិ គឺ:

១– ព្រះព្រហ្ម Brahma

២– ព្រះសិវៈ çiva

៣– ព្រះវិស្ណុ Visnu

និងមានទេវៈ បន្ទាប់បន្សំផ្សេងទៀត គឺ:

– ព្រះអាទិត្យ (ថ្ងៃ)

– ព្រះចន្ទ (ខែ)

– ព្រះគង្គា (ទឹក)

- ព្រះធរណី (ដី)
- ព្រះពាយ (ខ្យល់)
- ព្រះពិរុណ (ភ្លៀង)
- ព្រះអគ្គិ (ភ្លើង)
- ព្រះឥន្ទ្រ
- ព្រះយម
- ព្រះសូគ្រ:
- ព្រះកុវេរ:
- ព្រះកាលី ។ល។

ទេវ:ខាងលើនេះ ជាទេវ:បន្ទាប់បន្សំ ដែលពួកព្រាហ្មណ៍គោរពបូជា ។ ទេវ:ទាំងនេះ កើតចេញមកអំពីធម្មជាតិពិត ។ ។

## ក- ព្រះព្រហ្ម

**Brahma**

ក្នុងលទ្ធិព្រាហ្មណ៍ គេបានតម្កល់ទុកព្រះព្រហ្មជា

អាទិទេពបម្បងបំផុត ព្រោះព្រះព្រហ្មជាអ្នកបង្កើតលោកៈ ការៈ ធម្មជាតិទាំងអស់ និងគម្ពីរវេទ ពោលគឺព្រះព្រហ្ម ជាអាទិទេពសាងលោក (Dieu créateur du monde) ។

លក្ខណៈពិសេសសំគាល់ព្រះព្រហ្ម គឺ :

- មុខ ៤
- ដៃ ៤ កាន់គម្ពីរវេទ ឬកាន់ផ្កាឈូក
- កាយ សម្បុរក្រហម
- គេគន់គណ្ឌ : ថូផ្កា, ជាស, ស្លាបព្រា
- ពាហនៈ : សត្វហង្ស ជាយានជំនិះ
- មហេសី នាម សរស្វតី
- បុត្រ ៣ : ទក្សៈ, កត្តុ និង នាងសន្ធ្យា ។

## ខ- ព្រះសិវៈ Çiva

ព្រះសិវៈ មានន័យថា “ ក្សេមក្សាន្ត. ករុណា ”។

ព្រះសិវៈ កើតឡើងអំពីតំណក់លោហិត ដែលស្រក់ចុះ

តាកចិតៀមព្រះព្រហ្ម ។ ព្រះសិវៈ ជាអាទិទេពសាងលោកផង បំផ្លាញលោកផង (Dieu créateur et destructeur du monde). ។ ព្រះសិវៈមានព្រះនាមច្រើនយ៉ាងគឺ:

– ព្រះឥស្វរៈ (Içvara)

– ព្រះឥស្វរ

– ព្រះរុទ្រៈ (ruda)

– ព្រះហរៈ (Hara)

– ព្រះឧគ្រៈ (Ugra)

– ព្រះអឃោរៈ (Aghora)

– ព្រះភៃរវៈ (Bhairava)

– ព្រះមហេស្វរៈ (Maheçvara)

លក្ខណៈពិសេសសំគាល់ព្រះសិវៈគឺ :

– មុខ ១ អាចបែកភាគជាមុខ ៥

– ក ពណ៌ខៀវ

- កាយ សម្បុរស

- ភ្នែក ៣ : ភ្នែក ២ ដូចមនុស្សធម្មតា
  ឯភ្នែកទី៣ នៅចំកណ្ដាលថ្ងាស បិទជា
  និច្ចត្រឡេកនេះ ហៅថា «អគ្គិនេត្រ»

- សំលៀកបំពាក់ : ស្បែកខ្លា ឬស្បែកដំរី

- ដៃ ២ ឬ ១០

- ពាក់កម្រងឆ្អឹងលលាដ៍ក្បាល ជាគ្រឿងសំគាល់
  កប់កល្ប - យុគ

- ពាក់នាគជាសង្វារ ជាគ្រឿងសំគាល់កប់ឆ្នាំ

- ពាក់មួកមានព្រះចន្ទមួយចំណិតកង់កណ្ដៀវ ជា
  គ្រឿងសំគាល់កប់ខែ

- គេគងភ័ណ្ឌ : ត្រីសូល៍ , ខ្សែផ្ដាំ ឬ គទា (ដំបង)

- ពាហនៈ : គោនន្ទិ ជាយានជំនិះ

- មហេសី ឬ សក្តិ ៩ នាក់គឺ :

១– នាង ទុគ៌ា (durga) ស្រីចេះធ្វើមិនដឹងមិនឮ

២– នាងឧមា ( Uma ) ស្រីជាទីពេញចិត្ត

៣– នាងគៅរី ( Gauri ) ស្រីសម្បុរទង់ដែង

៤– នាងកាលី (Kali) ស្រីខ្មៅ

៥ – នាងចណ្ឌី ( Candi ) ស្រីកំណាច

៦– នាងបាវ៌តី ( Parvati ) ស្រីបុត្រីម្ចាស់ភ្នំ

៧– នាងកុមារី ( Kumari ) ស្រីក្រមុំព្រហ្មចារី

៨– នាងទេវី (devi) ស្រីទេពកញ្ញា

៩– នាងមហាទេវី ( Mahadevi ) ស្រីទេពអប្សរ ។

– បុត្រៈ ២ រូបគឺ ៖

១– ស្កន្ធៈ ( Skandha ) ទេវៈគំណាន់អ្នកស្រឡាញ់សង្គ្រាម

២– គណេស (Ganeça) ខ្លួនមនុស្ស ក្បាលដំរី

ទេវៈទាំងពីរនេះគឺ ៖ ស្កន្ធៈ និង គណេសៈ ជាបុត្រ

ព្រះសិវៈ និងនាងឧមា មហេសីដើម ។

– វិមាន : នៅលើកំពូលភ្នំកៃលាស ។

ម្យ៉ាងទៀត ក្នុងករណី ដែលព្រះសិវៈមាននាទីជាអ្នកសាងលោក នោះព្រះសិវៈបានវះកាត់ព្រះឧរូឲ្យលោហិតមួយតំណក់ស្រក់ចុះក្នុងទឹក កើតបានជាអណ្ឌៈ (ពង) រួចទ្រង់បំបែកអណ្ឌៈនោះជា ២ បំណែកគឺ :

– បំណែកខាងលើ ទ្រង់សាងជាស្ថានសួគ៌

– បំណែកខាងក្រោម ទ្រង់សាងជាមនុស្សលោក ។

បន្ទាប់មកទ្រង់បានសាងជាព្រហ្មៈ គឺវិញ្ញាណលោកៈ ។ ព្រហ្មៈ ក៏បានសាង ប្រជាបតី, ប្រជាបតី ក៏បានសាងមនុស្សលោក ត ៗ មក ហេតុបានជាមនុស្សពេញពិភពលោក ។

អាស្រ័យដំនៀមថា ព្រះសិវៈជាអ្នកសាងលោក បង្កើតលោក បិតាលោក នេះហើយ ទើបបានជាពួកព្រាហ្មណ៍បានសាងទុកជាទីរំឭកនូវរូប សិវលិង្គ ឬ លិង្គព្រះឥសូរ និង

យោនីនាងឧមា ជាទីគោរពសក្ការបូជា ទុកសំរាប់ធ្វើពិធីសិរ-ពគ្រី លាងបាបឧបទ្រពចង្រៃទាំងពួង ឲ្យជ្រះស្រឡះអំពីរូបរាងកាយ ។

* *

*

## សិវលិង្គ ឬ លិង្គព្រះឥសូរ

ដោយហេតុតែ មនុស្សប្រូលចិត្ត ស្រឡាញ់ និយម គោរព ព្រះឥសូរ កាន់តែមានចំនួនច្រើនឡើងៗ ពួកឥសូរ-និយម ក៏បានលើកតម្កើង តំកល់ព្រះឥសូរទុកជាអាទិទេព ខ្ពង់ខ្ពស់ ប្រសើរបំផុត មានមុខងារជាអ្នកបង្កើតលោក សាងលោក ធ្វើឲ្យលោកក្សេមក្សាន្តផង ជាអ្នកបំផ្លាញលោក ធ្វើឲ្យលោកវិនាសហិនហោចផង ។ ពួកឥសូរនិ-យម ក៏នាំគ្នាគោរពកោតខ្លាច ព្រះឥសូរ ដោយបានកសាង

ចដិមាំគរ ជានិមិត្តរូបនៃការបង្កបង្កើតលោកនៃព្រះឥសូរ គឺសិវលិង្គ ឬ លិង្គព្រះឥសូរ និងយោនី នាងឧមា ។ លិង្គព្រះឥសូរ ជានិមិត្តរូបនៃសូយម្ភូ គឺកំណើតឯងនៃព្រះឥសូរ ។

ក្នុងសិល្បៈខ្មែរ គេបានសាងលិង្គព្រះឥសូរអំពីថ្មរឹងពណ៌ស មានកង ៤ ជ្រុង , ៦ជ្រុង , ៨ជ្រុង ហើយគេតម្កល់ជានិច្ចកាល នៅលើយោនីនាងឧមា ( ទុកជាទម្រ ) ដែលជាកំស្តុតាងបង្ហាញ អំពីមរណភាព ព្រះឥសូរ នៅលើទ្រូងនាងឧមា ( ឬហៅថា ស្លាប់នៅលើបង្គង ) ក្នុងពេលរួមសង្វាស ។



ព្រះឥសូរ(សិវៈ)

## គ - ព្រះវិស្ណុ - Visṇu

ព្រះវិស្ណុ ជាអាទិទេព ស្រោចស្រង់លោក ទ្រទ្រង់លោក ចំរើនលោក ។ ព្រះវិស្ណុ តែងតែជួយរឹតយោធ ស្រោចស្រង់ លោកៈ មនុស្សលោក ឲ្យបានសេចក្ដីសុខ ចំរើន ។

ព្រះវិស្ណុ មាននាមច្រើនដោយឡែក :

- ព្រះនារាយណ៍ Nārāyana
- ភគវន្ត Bhagavanta
- ហរី Hari
- អនន្តៈ Ananta

លក្ខណៈ ពិសេសសំគាល់ព្រះវិស្ណុៈ

- ក្បាល ១
- ដៃ ២, ដៃ៤, ដៃ៨
- សំលៀកបំពាក់ : ពណ៌លឿង

– ពាហនៈ មានសត្វគ្រុឌ ជាយានជំនិះ

– មហេសិ ឬ សក្តិ ២ នាក់គឺ :

១– នាងលក្ស្មី ទេពធីតាតំណាងទ្រព្យសម្បត្តិ

២– នាងស្រី ទេពធីតាតំណាងសោភ័ណភាព

– បុត្រ ១ រូប នាម ព្រះកាមៈ (Kama)

– វិមាន : នៅស្ថានវៃកុណ្ឋៈ

– គេគងកណ្តូ : កងចក្រ, ដំបង, ផ្កាឈូក, ខ្សែ

សង្ខ ធ្នូ, ដាវ ។

ម្យ៉ាងទៀត ព្រះវិស្ណុ ជាទេវៈ ជួយដោះទុក្ខមនុស្ស

លោក តែងតែបានបែងភាគជាអវតារ (Avatára) ពល់ៗ

កប្ប ចុះមកជួយស្រោចស្រង់មនុស្សលោក ឲ្យបានផុត

អំពីទុក្ខលំបាក ។

# អវតារព្រះវិស្ណុ ១០

អវតារ ព្រះវិស្ណុ ឬ ព្រះនារាយណ៍បែងភាគចុះមកជួយ

មនុស្ស មានចំនួន ១០ ជាតិហើយគឺៈ

១– មត្ស្យ : Matsya – ជាត្រី ជួយស្រោចស្រង់ជីវិតមនុស្ស ឲ្យរួចអំពីទឹកជំនន់ ដែលបង្កើតឡើងដោយយក្ស ឈ្មោះ ហយគ្រីវៈ ។

២– កូម៌ : Kurma – ជាអណ្ដើក ជួយទ្រកំណល់ភ្នំមន្ទរៈ ឲ្យទេវតានិងយក្សយកនាគឈ្មោះវាសុកិៈ បង្វិលភ្នំក្នុងសមុទ្រទឹកដោះ ឲ្យខះរង់ស្ងួត ដើម្បីយកទឹកអម្រឹត (អម្ឫតៈ Amṛta ) ផឹកកុំឲ្យស្លាប់ ។

៣– វរាហ : Varaha – ជាជ្រូកព្រៃ បានបំផ្លាញហិរណ្យយក្សដែលប៉ុនប៉ងរំលាយលោកឲ្យទៅជាទឹកសមុទ្រ ។

៤– នរសិង្ហ : Narasinha – ជាមនុស្សសិង្ហ ក្បាលមនុស្ស ខ្លួនសិង្ហ បានបំផ្លាញយក្ស ដែលធ្វើបាបទេវតា ។

៥– វាមន : Vamana – ជាមនុស្សតឿ ចុះទៅប្រើកលល្បិច សុំដីយក្ស ៣ ជំហាន ទុកឲ្យមនុស្សនៅ ។

៦– បរសុរាម : Paraçurama – ជារាមពូថៅបាន

បង្ក្រាបក្សត្រអវដុខ ។

៧– រាម : Rāma – ជាព្រះរាម ក្នុងរឿងរាមាយណៈ បង្ក្រាបក្រុងរាពណ៍ ។

៨– ក្រឹស្ណ : Kṛsna ជាក្រឹស្ណៈ បានជួយមនុស្ស ឲ្យរួចអំពីកណ្ដាប់ដៃ ស្ដេចកំណាចឈ្មោះកម្សៈ (Kamsa) ក្នុងរឿងមហាភារតយុទ្ធ ។

៩– ពុទ្ធ : Buddha – ជាព្រះពុទ្ធ បានជួយស្រោចស្រង់ជាសំគៀនមនុស្ស ឲ្យស្គាល់បុណ្យបាប អាក្រក់ល្អ ផុតចាកបាបកម្ម ។

( តាមពិត ព្រះពុទ្ធពុំមែនជាអវតារ ព្រះវិស្ណុទេ តែពួកព្រាហ្មណ៍ ដោយបានឃើញព្រះពុទ្ធមានឥទ្ធិពល មានអានុភាពខ្លាំង ក៏បានបញ្ចូលជាអវតារព្រះវិស្ណុ) ។

១០– កល្កិន Kalkin – ជាមនុស្សសេះ គឺខ្លួនមនុស្ស ក្បាលសេះ បានចេញបង្ក្រាបពួកក្សត្រ ដែលធ្វើឲ្យមានចលាចល ។



ព្រះនារាយណ៍ (វិស្ណុ)

# វិធីប្រតិបត្តិក្នុងសាសនាព្រាហ្មណ៍

ពួកព្រាហ្មណ៍ តែងមានទស្សនៈយល់ថា: លោក: លោកធាតុ វត្ថុ ធម្មជាតិទាំងអស់ក្នុងលោក សុទ្ធតែកកើតឡើង ដោយសារអាទិទេព ៗ អាទិទេព បង្កើត ពុទ្ធិការ: សុខ: ៗ អាទិទេព អាចឲ្យសុខទុក្ខ អាក្រក់ល្អ ចំរើនវិនាស ដល់មនុស្សសត្វគ្រប់រូបទាំងអស់ ៗ មនុស្សគ្រប់រូប មានកំសមា ក្តីសំណាង ឬគ្មាន គឺស្រេចតែព្រហ្មលិខិត ដែលអាទិទេពបានគូសដៅមក ៗ បើអាទិទេពឲ្យរស់ ក៏បានរស់ បើអាទិទេពឲ្យស្លាប់ ក៏ត្រូវស្លាប់ ពុំអាចប្រកែកជជែកតវ៉ាបានឡើយ ៗ

ដោយមានជំនឿយ៉ាងនេះ ទើបពួកព្រាហ្មណ៍បាន បញ្ញត្តទស្សនៈថា មនុស្សម្នាក់ៗ ដើម្បីឲ្យបានសេចក្តីសុខសប្បាយ ត្រូវមានភក្តីភាព យ៉ាងមោះមុត ចំពោះអាទិទេព ហើយត្រូវប្រព្រឹត្ត ប្រតិបត្តិបត្តំនិតខ្លួន ឲ្យត្រូវតាមបំណង

និងស្របតាមព្រះទ័យអាទិទេព ។

ឯវិធី ដែលត្រូវប្រព្រឹត្ត ប្រតិបត្តិ បំពេញបំណាន់ បំពេញព្រះទ័យ អាទិទេព មានគោលសំខាន់ ៤ យ៉ាង គឺ:

១— ភក្តិ Bhakti ត្រូវមានភក្តីភាព

២— ការបំពេញ តប: និង យោគ:

៣— ពិធីបូជាយញ្ញ និង បូជាអគ្គី

៤— ពិធីសិវរាត្រី មុជទឹកលាងបាប

## ១– ភក្តិ – Bhakli

ភក្តិ : ត្រូវមានភក្តីភាពស្មោះត្រង់ចំពោះអាទិទេព ជឿចំពោះអាទិទេព ផ្ដោតចិត្តគំនិត ឲ្យបាញ់ឆ្ពោះតម្រង់ទៅរកអាទិទេព ស្និទ្ធស្នាល តម្រង់ចិត្ត ចំពោះតែអាទិទេព ដើម្បីឲ្យអាទិទេពផ្ដល់សេចក្ដីសុខឲ្យ តាមប្រាថ្នា ។

## ២– ការបំពេញតបៈនិងយោគៈ

តបៈ Tapa — ក្នុងផល់ការប្រព្រឹត្តិ ប្រតិប

ខ្លួនរាងកាយ ឲ្យល្អស្អាតបរិសុទ្ធ ប្រាសចាកគ្រឿងសៅហ្មង ដោយប្រព្រឹត្តដុតកំដៅខ្លួន អង្គុយអាំងភ្លើងយ៉ាងក្ដៅ ធ្វើខ្លួនឲ្យទុក្ខលំបាក ហើយតាំងចិត្តផ្ដោតតម្រង់ បាញ់ឆ្ពោះទៅរកអាទិទេព ដើម្បីធ្វើឲ្យអាទិទេពរំដើបរំជួល ឃើញសេចក្ដីព្យាយាមនិងកក្ដីភាព ដ៏មោះមុតរបស់ខ្លួន ក៏ប្រទានពរឲ្យបានសម្រេចតាមបំណង ៗ

យោគៈ **Yoga** – បានដល់ការប្រព្រឹត្តិ ប្រតិបត្តិខ្លួនអប់រំចិត្ត ឲ្យបានស្អាតបរិសុទ្ធ ក៏ជាតម្រង់ទៅរកអាទិទេព ក្នុងគោលបំណងឲ្យអាទិទេពជួយសន្ដោសប្រោសប្រណី ផ្ដល់សេចក្ដីសុខចំរើននិង ប្រទានពរតាមបំណងខ្លួន ៗ

## ៣-ពិធីបូជាយញ្ញ និងបូជាអគ្គី

ពិធីបូជាយញ្ញ – គឺជាពិធីបូជា ដោយយកមនុស្សសត្វទាំងរស់ ទៅដុតក្នុងគំនរភ្លើងឆេះសន្ធោសន្ធៅ ថ្វាយអាទិទេព ធ្វើឲ្យអាទិទេពសប្បាយចិត្ត ដែលជាហេតុនាំឲ្យអាទិទេព

ពេញព្រះទ័យ ហើយប្រសិទ្ធិពរឲ្យបានសុខចំរើន សមប្រ-
កបតាមបំណងប៉ងប្រាថ្នា ។

ពិធីបូជាអគ្គី — គឺជាពិធីបូជាភ្លើង ដោយដុតភ្លើងបំភ្លឺទាំងយប់ ទាំងថ្ងៃ ថ្វាយអាទិទេព ដើម្បីសុំពរឲ្យបានសេចក្ដីសុខសប្បាយ ។

## ៤ – ពិធីសិវរាត្រី - ពិធីលាងបាប

ពិធីសិវរាត្រី — គឺជាពិធីដែលគេធ្វើរលឹកដល់រាត្រីដែលព្រះឥសូរបានឲ្យកំណើតលោកៈ មនុស្សលោក ។ ពិធីនេះគេរៀបចំធ្វើតែក្នុងវេលាយប់ប៉ុណ្ណោះ ។ ពិធីសិវរាត្រីនេះក្នុង ១ ឆ្នាំ មានប្រារព្ធធ្វើតែមួយដង ។

នៅពេលយប់នៃពិធីនេះ គេនាំគ្នាទៅមុជទឹកក្នុងទន្លេគង្គាលាងបាប ចាំទ្រាំពេញត្រង់យ៉ាំង (ចំពោះអ្នកនៅប្រទេសឥណ្ឌាជិតទន្លេគង្គា) ដោយគេយល់ថា: ទន្លេគង្គា ជាមេទឹកស័ក្ដិសិទ្ធិ ហូរមកអំពីស្ថានសួគ៌ មានសីតុណ្ហភាពក្ដៅតិចៗ

(ឧណ្ហ)ល្មម ដើម្បីលាងជំរះបាបរបស់មនុស្សសត្វ ។ បន្ទាប់អំពីបានមុជទឹករួចហើយ គេក៏បានដងទឹកទន្លេគង្គានោះ យកទៅចាក់ស្រោចស្រប់លើលិង្គព្រះឥសូរ ( សិវលិង្គ ) ដែលគេបានដាក់តំកល់នៅលើយោនីនាងឧមា រួចគេក៏ត្រងទឹកដែលហូរ ចុះតាមប្រឡាយយោនីនាងឧមា យកទៅផឹក·ស្រោចស្រប់ក្បាល លុបមុខស្រឡាបខ្លួនប្រាណ ដើម្បីឲ្យមានសិរីសួស្តី មានជោគជ័យ បំបាត់ចង្រៃ ឧបសគ្គឧបទ្រពនិងបាបគ្រប់យ៉ាង ។

ពួកព្រាហ្មណ៍ ដែលមានកក្តីភាពនិងជំនឿមោះមុត វេលាទៀបស្លាប់ សុំឲ្យបានទៅស្លាប់នៅក្បែរទន្លេគង្គា ដើម្បីឲ្យគេដុតយកឆ្អឹង គ្រវែងបាចចោលក្នុងទន្លេគង្គា លាងបាបគ្រប់យ៉ាង ឲ្យព្រះស្អាតបរិសុទ្ធ កុំឲ្យសេសសល់ ។

ចំពោះអ្នកដែលនៅឆ្ងាយអំពីទន្លេគង្គា គេនាំគ្នាកំណត់យកទន្លេឬ ស្ទឹងណាមួយដែលនៅជិត សន្មតថាជា

ទេវគង្គា ហើយរៀបចំពិធីសិរីរកត្រីដូចខាងលើដែរ ។

រីឯនៅប្រទេសខ្មែរយើងវិញ សម័យអង្គរ ដោយសារឥទ្ធិពល សាសនាព្រាហ្មណ៍ គេក៏បានកំណត់យកស្ទឹងសៀមរាប សន្មតជាទន្លេគង្គា ដែលមានសីសប្រកត នៅក្នុង-លេន ។ ទឹកស្ទឹងនេះបានហូរកាត់លិង្គព្រះឥសូរ និងយោនីនាងឧមាដែលគេបានសាងដាក់តម្រៀប នៅពាសពេញបាតស្ទឹងគាបឱ្យមនុស្សបុះមុជ ឬផឹក តាមបំណងចំណូលចិត្តគ្រប់ពេលវេលា ដើម្បីឱ្យបានសិរីសួស្តីជ្រះចង្រៃគ្រប់យ៉ាង និង ជាឱសថ សំរាប់ព្យាបាលរោគថែមទៀត ។

* *

*

## វណ្ណៈ ៤ ក្នុងលទ្ធិព្រាហ្មណ៍

ពាក្យថា វណ្ណៈ គឺពណ៌សម្បុរ ពោលគឺការជ្រើសសំ-

សៀគប់ពាក់ពណ៌ផ្សេង ១ គ្នា ។

ក្នុងលទ្ធិព្រាហ្មណ៍ មានការបែងចែកវណ្ណៈមនុស្សជាជាន់ ជាថ្នាក់ ខ្ពស់ទាប ខុស ១ គ្នាជា ៤ ពួកដោយមានទស្សនៈថា រូបកាយមនុស្សគ្រប់រូប សុទ្ធតែត្រូវបានព្រះព្រហ្មសាងឡើងអំពីការផ្សេង ១ នៃរូបកាយព្រះព្រហ្មគឺ:

– មាត់ សាងជា ព្រាហ្មណ៍

– ទ្រូង សាងជា ក្សត្រ

– ភ្លៅ សាងជា ឈ្មួញ (វៃស្យៈ)

– ជើង សាងជា ទាសៈ កម្មករ (សូទ្រៈ)

ហេតុនេះ មនុស្សត្រូវបែកជា ៤ វណ្ណៈគឺ :

១– វណ្ណៈ ព្រាហ្មណ៍ ប្រើសំលៀគប់ពាក់ពណ៌ ស

២– វណ្ណៈ ក្សត្រ „ ក្រហម

៣– វណ្ណៈ វៃស្យៈ (ឈ្មួញ) „ លឿង

៤– វណ្ណៈ សូទ្រៈ (ទាសៈ កម្មករ) „ ខ្មៅ

# បញ្ហាពុទ្ធិ កាមៈ សុខៈ ក្នុងលទ្ធិព្រាហ្មណ៍

## អំពី ពុទ្ធិ– La connaissance

ពុទ្ធិ គឺចំណេះវិជ្ជា ការចេះដឹង យល់ស្គាល់នូវអ្វីមួយដោយជាក់ច្បាស់ ដោយសារពុទ្ធិប្រធាន បានលើកយកពុទ្ធិវត្ថុ មកត្រិះរិះពិចារណា សិក្សាស្រាវជ្រាវ ការរក ឲ្យឃើញច្បាស់តាមសភាពពិត ។

ពុទ្ធិទាំងអស់ សុទ្ធតែមានសភាពលក្ខណៈ ខ្ពស់ទាប ខុសៗគ្នា ប៉ុន្តែពុទ្ធិដ៏ប្រសើរខ្ពង់ខ្ពស់ សក្តិសិទ្ធិ, តាមលទ្ធិព្រាហ្មណ៍ គឺពុទ្ធិដែលកើតឡើងអំពីអាទិទេព ព្រោះអាទិទេព ជាអ្នកចេះដឹងសព្វ (សព្វញ្ញូ) បរិសុទ្ធស្អាតហើយជាពិសេសគឺ ពុទ្ធិដែលមាននៅក្នុងគម្ពីរវេទទាំង ៤ គឺ: ឫគ្វេទ, សាមវេទ, យជុវេទ, អថវ៌វេទ ដែលជាអំណោយអាទិទេព ។

អ្នកដែលមានសិទ្ធិ ទទួលយកពុទ្ធិគឺៈ វណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រ តែពីរពួកនេះប៉ុណ្ណោះ ។

## អំពីភាវៈ— L'Être

ភាវៈ គឺលោកៈ ទេវៈ អាទិទេព បិត្ត អាត្មន មនុស្ស សត្វ ដី ទឹក ភ្លើង ខ្យល់ អាកាស ធម្មជាតិ វត្ថុជាតិ ។ល។ ដែលកើតមានឡើង. ដុះដាលឡើង ។

ភាវៈទាំងអស់សុទ្ធតែកើតឡើង សាងឡើងដោយ អំណាចឥទ្ធិឫទ្ធិ អាទិទេព គឺ អាទិទេពជាអ្នកសាងភាវៈ ទាំងអស់ ។

តាមទស្សនៈពួកព្រាហ្មណ៍យល់ថា៖ អាទិទេពដែល ជាអ្នកសាងលោក បង្កើតលោកៈ ភាវៈ គឺ ព្រះព្រហ្ម ។ ដំបូងព្រះព្រហ្មបានដប់ឲ្យកើតជាស៊ុតមួយ ហៅថា " ពង ព្រហ្ម " អណ្តែតក្នុងលំហអាកាស អស់កាលជាយូរអង្វែង ឆ្នាំ រួចទ្រង់បំបែកស៊ុតនោះជាបំណែក ដោយយកបំណែក ខាងលើសាងជាមេឃ ហើយបំណែកខាងក្រោមសាងជា ផែនដី ។ បន្ទាប់មក ព្រះព្រហ្មបង្កើតឲ្យមានភ្លើងឆេះផែន

ដី រូបទ្រង់បង្កើតឲ្យមានទឹកមកលត់ភ្លើង លុះភ្លើងរលត់ ទឹកបានធ្វើឲ្យដីមានដំរជាតិ ជាហេតុបណ្ដាលឲ្យមានមនុស្ស សត្វ រុក្ខជាតិ ធម្មជាតិ ជាដើម ពាសពេញលើពិភពលោកៗ

គាវៈទាំងអស់ សុទ្ធតែកើតឡើង ដោយសារអាទិទេព ហើយតែងតែប្រែប្រួល ផ្លាស់ប្ដូរមានសភាព ពុំទៀងទាត់ឋិត ថេរទេ គឺតែងតែវិលកើតវិលស្លាប់ជាដរាប ។ មានតែអាទិ-ទេព និង អាត្មន ប៉ុណ្ណោះ ដែលទៀងទាត់ឋិតថេរជានិច្ចកាល ពុំចេះស្លាប់ ព្រោះគាវៈទាំងពីរនេះកើតឯង ។

អំពីសុខៈ– **Le Bonheur**

សុខៈ សេចក្ដីសុខ សប្បាយ រីករាយ សុខកាយ សប្បាយចិត្ត មានសុភមង្គល ។

សុខៈ មាន ២យ៉ាងគឺៈ

១– សាមញ្ញសុខ - សេចក្ដីសុខធម្មតា មានការប្រែ ប្រួលផ្លាស់ប្ដូរ លាយឡំដោយទុក្ខ សុខប្រឡូកប្រឡល់ ជា

សេចក្ដីសុខពុំបរិសុទ្ធ ដែលមាននៅក្នុងលោកនេះ មនុស្សលោក ស្គាល់ស្រួល ។ សាមញ្ញសុខ គឺជាសេចក្ដីសុខខាងកាយ ឬ ជាសេចក្ដីសុខបន្ទំ ។

២- បរិបុណ្ណសុខ Le Bonheur absolu - គឺជាសេចក្ដីសុខដ៏បរិសុទ្ធ ពិតប្រាកដ គ្មានប្រែប្រួល គ្មានផ្លាស់ប្ដូរ គ្មានណាយទៀតដោយទុក្ខ គ្មានភាពច្របូកច្របល់ ពោលគឺ ជាសេចក្ដីសុខពិត ដែលមាននៅក្នុងអាទិទេព ។

សេចក្ដីសុខ ទាំងពីរយ៉ាងខាងលើនេះ សាមញ្ញសុខក្ដី បរិបុណ្ណសុខក្ដី, តាមទស្សនៈលទ្ធិព្រាហ្មណ៍ មនុស្សពុំអាចនឹងបង្កើតឡើង ដោយខ្លួនឯងបានឡើយ ព្រោះសុខៈនេះឋិតនៅក្នុងកណ្ដាប់ដៃអាទិទេព ។ ហេតុនេះ ដើម្បីឲ្យបានសេចក្ដីសុខ មនុស្សម្នាក់ ៗ ត្រូវមានភក្ដីភាព ស្មោះត្រង់ចំពោះអាទិទេព ហើយបួងសួងអង្វរករ បន់ស្រន់ សុំអាទិទេពដោយធ្វើពិធីបូជាយញ្ញ បូជាអគ្គី ថ្វាយអាទិទេព បំពេញព្រះ

ទ័យអាទិទេព ធ្វើឲ្យអាទិទេព សប្បាយចិត្ត ទ្រង់នឹងផ្តល សេចក្តីសុខឲ្យមនុស្ស តាមត្រូវការ ។

ជាពិសេស ដើម្បីបានបរិបុណ្ណសុខ ដែលជាសេចក្តីសុខកំពូល សុខពិត នោះមនុស្សម្នាក់ៗ ត្រូវតែខំប្រឹងប្រ-ព្រឹត្តប្រតិបត្តិ ឲ្យបានត្រឹមត្រូវតាមវិធី ២ យ៉ាង ដ៏ប្រសើរគឺ:

១- តបៈ **Tapa** - ការអប់រំ ខ្លួនឯងកាយដោយដុតកំដៅ កម្ដោចពងកាយ ឲ្យរីងស្ងួតកិលេសគ្រឿងសៅហ្មងគ្រប់យ៉ាង ដើម្បីឲ្យបានស្អាតល្អបរិសុទ្ធ រួចផុតចាកទុក្ខទាំងពួង មានតែសេចក្តីសុខ ។

២- យោគៈ **yoga** – ការព្យាយាម ហាត់ពត់អប់រំចិត្តឲ្យបានស្អាតបរិសុទ្ធ ផូរផង់ ប្រាសចាកគ្រឿងសៅហ្មងគ្រប់យ៉ាង ផ្ចង់ស្មារតី ផ្ចង់ចិត្ត ឲ្យឋិតនៅក្នុងអំពើល្អ វៀចាកអំពើអាក្រក់ អំពើបាបអកុសលគ្រប់យ៉ាង ហើយតម្រ ចិត្តឲ្យបាញ់ឆ្ពោះទៅរកអាទិទេព តែមួយគត់ដោយអារម្មណ៍

នឹងនឹ៍ ៗ កាលបើអារម្មណ៍បិតជាប់នឹងអាទិទេព ហើយ ពេលនោះ ចិត្តក៏មានរស្មីភ្លឺភ្លឺថ្លាឆ្លង់ អាចឆ្លុះមើលឃើញច្បាស់នូវអាត្មន៍ របស់ខ្លួន ហើយមានលទ្ធភាពនឹងរុញច្រានអាត្មន៍ ឲ្យវិលចូលទៅរកព្រហ្មន៍វិញ ផុតចាកទុក្ខ លែងវិលកើតស្លាប់តទៅទៀត គឺ មោក្ស: មានបរិបុណ្ណសុខៈ តែម្យ៉ាង ៗ

## អាត្មន៍ - L'âme

អាត្មន៍ គឺ ជាឯកធាតុមួយពិសេស ដែលបែកចេញមកអំពីព្រហ្មន៍ ចូលមកសណ្ឋិតក្នុងរូបកាយមនុស្សសត្វគ្រប់រូបក្នុងលោកៈ ៗ អាត្មន៍ និង ព្រហ្មន៍ គឺជាធាតុតែ១ដែលប្រៀបដូចទឹកសមុទ្រ ហើយនិងទឹកសន្សើម ជាធាតុទឹកតែមួយដូចគ្នា ពុំមានទឹកណាជាមេទឹកណាជាកូនសោះឡើយ ៗ

ប៉ុន្តែ អាត្មន៍នេះ កាលបើឃ្លាតចេញអំពីព្រហ្មន៍ ហើយពុំងាយនឹងវិលត្រឡប់ចូលទៅរកព្រហ្មន៍វិញ បានដោយងាយស្រួលទេ ពីព្រោះមានបាបកម្ម មករាំងស្កាត់ដំណើរអាត្មន៍ៗ

បាបកម្ម បានបណ្ដាលឲ្យអាត្មន ទទួលទុក្ខវេទនា ផ្សេងៗ តាមរូបកាយដែលអាត្មនបានទៅសណ្ឋិតនៅ ហើយដែលធ្វើឲ្យអាត្មនចេះតែវិលវល់ ត្រឡប់ចុះត្រឡប់ឡើង វិលទៅវិលមក ពុំមានទីបំផុតឡើយ ។ ដូនកាលអាត្មន ចូលទៅស្ថិតនៅក្នុងរូបកាយមនុស្ស ដូនកាលក្នុងរូបកាយសត្វ ដែលមិនងាយនឹងគេចផុតអំពីការវិលវល់ ប្រឡូកប្រឡល់អន្ទោលចុះឡើងនេះឡើយ ។ ប្រៀបដូចជា ទឹកសន្សើម ដែលកើតចេញមកអំពីចំហាយទឹកសមុទ្រ ( Vapeur d'eau ), កាលបើឃ្លាតចេញអំពីសមុទ្រហើយ ក៏ធ្លាក់ចុះមកលើផែនដី ពុំងាយនឹងបានហូរត្រឡប់ចូលទៅក្នុងសមុទ្រវិញ បានដោយងាយឆាប់រហ័សទេ ពីព្រោះដូនកាលទឹកសន្សើមនេះ ជ្រាបចូលទៅក្នុងដី ក្នុងរុក្ខជាតិ ដូនកាល ធ្លាក់ចុះក្នុងទន្លេ ឬ ហូរចូលក្នុងអណ្ដូង ដែលត្រូវមនុស្សសត្វ ផឹក ប្រើប្រាស់ ហើយក៏ចេញអំពីមនុស្សសត្វ ទៅកាន់ទីផ្សេងៗទៀត វិលចុះវិលឡើង ពុំចេះចប់

ចេះហើយ ចេះតែវិលត្រឡប់ចុះ - ឡើងគ្មានទីបំផុត ។

ម៉្យាងទៀត ដើម្បីនឹងរុញច្រាន កាត់ឲ្យដាច់វិលត្រឡប់ទៅកេត្រហ្ម័នវិញ, តាមបរទះព្រាហ្មណ៍ បញ្ជាក់ប្រាប់ថា មនុស្សម្នាក់ ៗ ត្រូវតែខំប្រឹងសាងអំពើល្អ កុសលកម្ម ហើយនិងខំសំអាតកាយវាចាចិត្ត ឲ្យបានស្អាតបរិសុទ្ធ ផូរផង់ ប្រាសចាកគ្រឿងសៅហ្មងគ្រប់យ៉ាង ដោយប្រព្រឹត្ត ប្រតិបត្តិយ៉ាងតឹងរឹង តឹមត្រូវ ម៉ត់ចត់ នូវតបៈនិងយោគៈ ដែលជាវិធីដោះអាត្ម័ន ចេញអំពីបាបកម្ម អំពី វដ្តសង្សារ ។ មិនតែប៉ុណ្ណោះ តបៈ និងយោគៈ នេះ ជាមាគ៌ានាំអាត្ម័ន ឲ្យបានចូលទៅដល់ព្រហ្ម័នវិញ ។ កាលបើអាត្ម័ន បានជួបព្រហ្ម័នហើយ អាត្ម័នលែងវិលត្រឡប់ចូលមកនៅក្នុងរូបកាយមនុស្សសត្វ លែងជួបប្រទះនឹងទុក្ខវេទនា តទៅទៀតហើយ ឈ្មោះថារួចផុតអំពីសង្សារវដ្ត គឺមោក្សៈ មានបរិបុណ្ណសុខដ៏បរិសុទ្ធតែម្ញ៉ន ៗ

# សំសារៈ ឬ សំសារវដ្ត

( សង្សារវដ្ត )

សំសារវដ្ត " ដំណើរអន្ទោលទៅមក វិលកើតវិល-ស្លាប់ " ឬ " ដំណើរកើតស្លាប់ ស្លាប់កើត វិលវល់ចុះឡើងប្រៀបដូចជាកង់ចក្រ " ។

តាមទស្សនៈពួកព្រាហ្មណ៍ៈ ក្នុងសង្សារវដ្ត ត្រូវមានវិញ្ញាណអាត្ម័នវិលកើត វិលស្លាប់ ដែលកើតចេញមកអំ-ពីបឋមវិញ្ញាណ គឺព្រះព្រហ្ម (ព្រះហ្ម័ន) ប្រៀបដូចជាផ្កាភ្លើង ដែលខ្ទាតចេញអំពីរងើកភ្លើង ឬ ប្រៀបដូចជាដំណក់ទឹកភ្លៀង ដែលកើតចេញមកអំពីទឹកសមុទ្រ ។ វិញ្ញាណអាត្ម័ននេះ កម្រនឹងមានឧកាសត្រឡប់ចូលទៅរកព្រហ្ម័នវិញបានដោយងាយឡើយ ពីព្រោះវិលតែកើតស្លាប់ ស្លាប់កើត អន្ទោលទៅមកពុំមានទីបំផុតឡើយ ជួនកើតជាមនុស្ស ជួនជាសត្វ ជាទេវជាតិ ជាព្រហ្មជាតិ ។ល។

គេកំណត់ឲ្យទៀងទាត់ពុំបានឡើយ ។

អាស្រ័យហេតុនេះ មនុស្ស សត្វគ្រប់រូប ទោះតែកើត ស្លាប់ អណ្តែតអណ្តូងវិលវល់ទៅមក ជួនបានល្អ ខ្ពង់ខ្ពស់ ជួនបាន អាក្រក់ ទុក្ខវេទនា ទាបថោក ផ្លាស់ប្តូរវេនគ្នាចុះឡើងពុំចេះចប់ ដែលបណ្តាលមកតែអំពីកម្មៈ ។

## កម្មៈ – Karma

អំពើ ឬ ទង្វើរបស់មនុស្សម្នាក់ៗ ល្អក្តី អាក្រក់ក្តី ដែលបានប្រព្រឹត្តកើតឡើងដោយកាយ វាចា ចិត្ត ហៅថាកម្មៈ មាន ២ យ៉ាងគឺ :

១– កម្មៈ ដែលមនុស្សធ្វើរួចហើយ តែពុំទាន់ហុចផល

២– កម្មៈ ដែលមនុស្សកំពុងតែធ្វើ ព្រមទាំងហុចផលឲ្យ ។

កម្មៈទាំងពីរយ៉ាងនេះ ដែលមនុស្សណាមួយបានធ្វើរួចហើយ ល្អក្តី អាក្រក់ក្តី ក្នុងជាតិនេះឬក្នុងអតីតជាតិ តែង

តែប្រែក្លាយទៅជាផលផ្តល់ឲ្យអ្នកធ្វើ អ្នកប្រព្រឹត្តគង់ពេលកាលមួយរមែងតាមតបាំងកម្មៈ ថ្មី ឬ ព្រោល ក្នុងបច្ចុប្បន្នជាតិ ឬ ក្នុងអនាគតជាតិ ។ ដោយសារកម្មនេះ ដែលជាឧបសគ្គកំពង់ស្ទាក់ដំណើរកេត្តិ៍ន មិនឲ្យវិលត្រឡប់ចូលទៅកេព្រហ្មទវិញបានដោយងាយតឹ កម្មនេះ តែងតែធ្វើឲ្យសត្វទវិលវល់អន្ទាលកើតស្លាប់គ្មានទីបំផុត ក្នុងសង្សារវដ្តដ៏ធំជេងគ្មានគោះត្រើយ ។

*

* *

## លទ្ធិទេព - លទ្ធិព្រាហ្មណ៍ក្នុងសង្គមខ្មែរ

ឥទ្ធិពលលទ្ធិទេព លទ្ធិព្រាហ្មណ៍ ឬ សាសនាព្រាហ្មណ៍ បានបង្កើតជាជំនឿផ្សេងៗ ពាក់ព័ន្ធយ៉ាងមាំក្នុងសង្គមខ្មែរ ចិត្តគំនិតខ្មែរ ទំនោរខ្មែរ មនោសាស្ត្រខ្មែរ មនោគមខ្មែរ

តាំងពីគតិយោគថ្មីចូលមកហើយ រហូតមកដល់បច្ចុប្បន្ន ។ ជាពិសេស ឥទ្ធិពលនៃលទ្ធិនេះ មានបែកទៅជាភាគគឺ:

– ជំនឿ

– ទំនៀមទម្លាប់ - ប្រពៃណី

– សិល្បៈ

– អក្សរសិល្ប៍

## ១– ជំនឿ – Croyance

ជំនឿថា: សុខ ទុក្ខ ការក្រក់ ល្អ កើតឡើងបានដោយសារ ទេវតា ទេវៈ កាចំទេត ជាអ្នកផ្តល់ឲ្យ ។ ពិសេស ជំនឿ ខ្មោច ព្រាយ បិសាច រាក្ស អ្នកតា បង់បត់ មេមត់ សែនព្រេន សុំសេចក្តីសុខចំរើន ។

## ២–ប្រពៃណី–ទំនៀមទម្លាប់

**Coutume - Mœurs**

ក្នុងសង្គមខ្មែរ មានប្រពៃណី ទំនៀមទម្លាប់ ច្រើន

យ៉ាងណាស់ ដែលមានទំនាក់ទំនងនិងលទ្ធិវេទ លទ្ធិព្រាហ្មណ៍ សាសនាព្រាហ្មណ៍ ដូចជា :

- ពិធីបុណ្យទាន ដែលមានរៀបចំធ្វើស្លាធរ បាយសី ជាដើម ។

- ពិធីអាពាហ៍ពិពាហ៍ ដែលមានការរើសពេលា ចូលកោនបុម្ព , ធ្វើកនទេពតា ក្រុងពាលី ជាដើម ។

- ស្ថាបនកម្ម រៀបសង់ផ្ទះ មានការរើសពេលាលើក ដោយមានរៀបពិធីសែនព្រេនថ្វាយទេពតា ជាដើម ។

- ពិធីបូជាសព ដែលមានធ្វើពិធីវិកលសព ហែសព បញ្ចុះសព តាមក្បួនខ្នាតជាដើម ។

- ពិធីព្យាបាលជម្ងឺ ដែលមានពិធីដុតធូប សំពះដុំថ្ម អន្ទរគរ បន់ស្រន់ សុំឲ្យជាសះស្បើយ លៀងអារក្ស សុំឲ្យគ្រោចជួយជាដើម ឬរៀបចំធ្វើជាពិធីហៅព្រលឹង អញ្ជាក់ព្រលឹង អ្នកជម្ងឺ ជាដើម ។ល។

## ៣- សិល្បៈ - L'art

សិល្បៈខ្មែរ ជាច្រើនដែលមានទំនាក់ទំនងនឹងសាសនាព្រាហ្មណ៍ ដូចជា:

ក- គំនូរ- ចម្លាក់: មានគំនូរ ចម្លាក់ជាច្រើនដែលគូរ ឆ្លាក់យកលំនាំតាមបែបរឿងរ៉ាវ ក្នុងសាសនាព្រាហ្មណ៍ មានរឿង រាមាយណៈ មហាភារតយុទ្ធ ជាដើម ដូចជា:

រូបព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ព្រះកាម ព្រះឥន្ទ្រ ព្រះអគ្និ ជាដើម ។

ខ- ប្រាសាទ: ប្រាសាទបុរាណខ្មែរ ជាបូជនីយដ្ឋានដែលមានទំនាក់ទំនងនឹងសាសនា ។ មានប្រាសាទជាច្រើនដែលគេសង់ឡើង ឧទ្ទិសថ្វាយសាសនាព្រាហ្មណ៍ៗ ប្រាសាទខ្លះ គេសាងឧទ្ទិសថ្វាយព្រះឥសូរ (សិវៈ) ដូចជាប្រាសាទ:

បែបសំបុរ សតវត្សទី ៦ នៃ គ.ស.

- ប្រាសាទសំបូរព្រៃគុក - ប្រាសាទកុកជំ
- ប្រាសាទដំបងដែក ។

បែបព្រៃក្មេង សតវត្សទី ៧ នៃ គ.ស.

- ប្រាសាទព្រៃក្មេង - ប្រាសាទអណ្តែត
- ប្រាសាទស្វាយព្រហ្មណ៍

បែបកំពង់ព្រះ សតវត្សទី ៨ នៃ គ.ស.

- ប្រាសាទកំពង់ព្រះ - ប្រាសាទអកយំ
- ប្រាសាទត្រពាំងផុង - ប្រាសាទកូមិប្រាសាទ

## ប្រាសាទសម័យអង្គរ :

បែបកុលែន ដើមសតវត្សទី ៩ នៃ គ.ស.

- ប្រាសាទដំរីក្រាប - ប្រាសាទអូបាផ
- ប្រាសាទទួលស្វាប់ - ប្រាសាទរូបអារក្ស
- ប្រាសាទថ្មដាប - ប្រាសាទគគី
- ប្រាសាទក្រហម - ប្រាសាទអ្នកតា ។

បែបព្រះគោ មុនសតវត្សទី ៩ នៃ គ.ស.

- ប្រាសាទព្រះគោ - ប្រាសាទបាគង
- ប្រាសាទលលៃ ។

បែបបាខែង មុនសតវត្សទី ៩ នៃ គ.ស.

- ប្រាសាទភ្នំបាខែង - ប្រាសាទភ្នំក្រោម
- ប្រាសាទភ្នំបូក - ប្រាសាទភ្នំក្រហ៉ម
- ប្រាសាទប្រែរូប ។

បែបកោះកេរ ដើមសតវត្សទី ១០ នៃ គ.ស.

- ប្រាសាទកោះកេរ

បែបបន្ទាយស្រី មុនសតវត្សទី ១០ នៃ គ.ស.

- ប្រាសាទបន្ទាយស្រី - ប្រាសាទស្រឡៅ

បែបឃ្លាំង ដើមសតវត្សទី ១១ នៃ គ.ស.

- ប្រាសាទឃ្លាំង - ប្រាសាទតាកែវ
- ប្រាសាទវិមានអាកាស - ប្រាសាទភ្នំជីសូរ

- ប្រាសាទព្រះវិហារ - ប្រាសាទចៅស្រីវិបុលៗ

ម្យ៉ាងទៀត មានប្រាសាទជាច្រើន ដែលគេ

កសាងឧទ្ទិសថ្វាយព្រះនារាយណ៍ (វិស្ណុ) ដូចជា:

- ប្រាសាទអង្គរវត្ត - ប្រាសាទបន្ទាយសំរែ

- ប្រាសាទព្រះពិធូរ - ប្រាសាទចម្ការខ្ទិ

- ប្រាសាទវត្តអត្តា - ប្រាសាទចៅសាយ

- ប្រាសាទបេងមាលា - ប្រាសាទបាលិលេយ្យ

- ប្រាសាទមេបុណ្យខាងលិច (នៅក្នុងបារាយណ៍)។

រីឯលក្ខណៈប្រាសាទបែបព្រាហ្មណ៍និយម គេអាច

សំគាល់បានដោយសារ:

១- គេច្រើនសង់ប្រាសាទនៅលើកំពូលភ្នំ ឬ នៅលើ

ដីទួលខ្ពស់ ។

២- គេតម្កល់លិង្គព្រះឥសូរ នៅលើយោនីនាងឧមា

ក្នុងប្រាសាទ ។

# ៤-អក្សរសិល្ប៍

**Littératures**

អត្ថបទ អក្សរសិល្ប៍ជាច្រើន ដែលមានទំនាក់ទំនង នឹងសាសនា ព្រាហ្មណ៍ ជាចលនា • ព្រាហ្មណ៍និយម ដែលច្រើនតែដកស្រង់យកជំនឿផ្សេងៗ ក្នុងលទ្ធិព្រាហ្មណ៍ មករៀបរាប់ពន្យល់ បង្ហាញ ព្រមទាំងលើកយក អច្ឆរិយៈ-បុគ្គល ទេវៈ ទេវតា អាទិទេព ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ យក្ស គន្ធព ជាដើម ៗ ជាពិសេស អក្សរសិល្ប៍ផ្នែកនេះ ច្រើនលើកយក មន្តអាគម គាថា អួមអាម បែនការ បំបាំងបាត់ បេះដប់ បេះក្រោស ហោះហើរ ដើរលើអាកាស ជាដើម ៗ

១. ដូចជា រឿងរាមកេរ្តិ៍ រឿងជិនវង្ស រឿងវរវង្សសូរវង្ស រឿងទេពនាវង្ស ទិព្វសង្វារ ខ្យងស័ង្ខជាដើម ៗ ល ៗ

# លក្ខណៈពិសេសគួរចំណាំ ក្នុងអក្សរសិល្ប៍ បែបព្រាហ្មណ៍និយម

១– ផ្ដើមរឿង : សរសើរ គុណបុណ្យបារមី ឫទ្ធិ អំណាច ឥសី ឥស្សូរ ទេវៈ អាទិទេព ឬ រៀបរាប់អំពី ទេសភាព ព្រៃព្រឹក្សា ដែលនៅជុំវិញ អាស្រម មុនីឥសីៗ

២– ដំណើររឿង : ក្នុងដំណើររឿង បានបង្ហាញអំពីៈ

ក– តួអង្គ ១– តួឯក : ប្រុសជាអវតារព្រះនារាយណ៍ ឬ ជាកំពូលបុរស ។

: ស្រីជាកំពូលនារី ស្រីល្អឯក ។

២– តួរង : មានយក្ស ស្ដេច គ្រុឌ នាគ ទេវតា គន្ធព្វ ឥសី ឥស្សូរ ជាដើម ។

១– ទីកន្លែងតួអង្គ : ក្រុងអយុធ្យា, ក្រុងលង្កា, នគរ តក្កសិលា, ស្ថានសួគ៌, ស្ថានកៃលាស, បាតាល, ស្ថានភុជង្គនាគ

ជាដើម ។

ក- បញ្ហាចោទ : ទំនាស់វិបត្តិកើតឡើង ដោយសារ:

- សការៈល្អ ប្រឆាំងនឹង សការៈអាក្រក់ ។

- ការប្រណាំងប្រជែងគ្នាខាងយុទ្ធសិល្ប៍-សិល្ប៍សាស្ត្រ

- ការដណ្តើមអំណាចទ្រព្យសម្បត្តិគ្នា ។

- ការដណ្តើមស្នេហាគ្នា ។

ខ- បញ្ហាដោះស្រាយ : ប្រើយុទ្ធវិធី សង្គ្រាម កម្លាំងបាយ សំឡុតគំរាមកំហែង សងសឹក កាប់ចាក់ សម្លាប់គ្នាទៅវិញទៅមក ។

ង- បញ្ហាស្នេហា : ស្នេហាពុំបរិសុទ្ធ ពុំស្មោះត្រង់ ប្រណែន ប្រចណ្ឌ ឈ្នានីស ។

ច- គតិរឿង : ច្រើនអប់រំបង្រៀនមនុស្សឲ្យ:

- មានជំនឿចំពោះ ទេវៈ ទេវតា អាទិទេព ព្រះឥន្ទ ព្រះព្រហ្ម ថាជាអ្នកមានឫទ្ធិអំណាច ជួយឲ្យបានសុខ

ចំរើន មានសិរីសួស្តី ។

-មានចិត្តគំនិត អាត្មានិយម ប្រកាន់បក្សពួក ក្រុមគ្រួសារ ។

-មានចិត្តព្យាបាទ គំនុំគុំគួន សងសឹកគ្នា ទៅវិញទៅមកគ្មានទីបញ្ចប់ ដែលជាហេតុនាំឲ្យប្រាសចាកសីលធម៌មនុស្សធម៌ ។

-មានជំនឿថា សុខទុក្ខ អាក្រក់ល្អ មានក្រសុខ្ខតែកើតមានមកដោយសារទេវតា អាទិទេព ជាអ្នកផ្តល់ឲ្យ ដែលជាហេតុនាំឲ្យមនុស្សខ្វះការតស៊ូ ខ្វះព្យាយាម ខ្វះវិចារណញ្ញាណ ។

៣- បញ្ចប់រឿង: គេបញ្ចប់រឿងក្នុងខណៈ ដែលតួអង្គតំណាងសភាវៈល្អ បានទទួលជោគជ័យ ជ័យជំនះជាស្ថាពរ លើតួអង្គតំណាងសភាវៈអាក្រក់ ។

អាស្រ័យហេតុនេះ យើងឃើញថា ឥទ្ធិពល

សាសនាព្រាហ្មណ៍ បានគ្រប់ដណ្តប់ ចាក់ឫសយ៉ាងមាំ ក្នុងចិត្តគំនិតខ្មែរ ទំនោរខ្មែរ សង្គមខ្មែរ រហូតដល់ធ្វើឲ្យខ្មែរខ្លះវង្វេង យល់ច្រឡំ ខ្វះសតិសម្បជញ្ញៈ ខ្វះស្មារតីមនុស្សនិយម ពឹងផ្អែកទៅលើកម្លាំងឥទ្ធិពលទេពតា ព្រះឥន្ទ្រ ព្រះព្រហ្ម ខ្មោចព្រាយ បិសាច ជាដើម ដោយមានជំនឿយ៉ាងមុតមាំ ថាជាអ្នកផ្តល់សេចក្តីសុខសុភមង្គលឲ្យខ្លួន ។

ចប់លទ្ធិព្រាហ្មណ៍ដោយសង្ខេប

* *

*

# ពុទ្ធសាសនា

## Buddhisme

ពុទ្ធសាសនា គឺជាពាក្យទូន្មាន ប្រៀនប្រដៅរបស់ព្រះពុទ្ធ ជួយណែនាំ ពន្យល់ អប់រំ រំលឹក ដាស់តឿនមនុស្ស ឲ្យស្គាល់បុណ្យបាប ល្អអាក្រក់ ។ ពុទ្ធសាសនា គឺជាឈ្មោះលទ្ធិមួយធំ ដែលមានកំណើត ២៥៦០ ឆ្នាំហើយ គឺ ៥៤៩ឆ្នាំមុន គ.ស ។ គោលពុទ្ធសាសនាធំៗ មានពាក្យគឺៈ

១– ការមិនធ្វើអំពើអាក្រក់ (បាប) គ្រប់យ៉ាង ។

២– ការសាងធ្វើបំពេញអំពើល្អ (បុណ្យ កុសល) ។

៣- ការអប់រំចិត្ត ឲ្យបានស្អាតបរិសុទ្ធផូរផង់ ប្រាសចាកលោភៈ ទោសៈ មោហៈ ។

គោលទាំង ៣ ខាងលើនេះ ជាពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ ឬហៅថា ពុទ្ធសាសន៍ ។



# តើព្រះពុទ្ធជាអ្វី ?

មុននឹងសិក្សាអំពីគោលលទ្ធិពុទ្ធសាសនា តទៅទៀត គួរគប្បីតែស្គាល់ព្រះពុទ្ធជាមុន ព្រមទាំងសិក្សាយល់ ដឹងខ្លះអំពី ជីវប្រវត្តិព្រះពុទ្ធ អំពីឆាកជីវិតព្រះពុទ្ធ ពោះបើជាយើងពុំបានរស់នៅ ក្នុងសម័យកាលជាមួយនឹងព្រះពុទ្ធក៏ដោយ ក៏យើងអាចដឹងស្គាល់ព្រះពុទ្ធ ដោយសារឯកសារផ្សេងៗជាប្រវត្តិសាស្ត្រ ជារូបគំនូរ ជាចម្លាក់ ជាបដិមាករដ៏សំខាន់ៗ ដែលគេបានចងក្រង សាងទុក មកជាយូរយារដូចជា :

- ការប្រសូតនៃព្រះពុទ្ធ ។
- ការជួបប្រទះនឹងហេតុទាំង ៤ គឺ: មនុស្សចាស់ ឈឺ ស្លាប់ បព្វជិត ។
- ការចេញសាងផ្នួស ។
- ការធ្វើទុក្ករកិរិយា ស្វែងរកមោក្ខធម៌ ។
- ការប្រយុទ្ធចម្បាំងនឹងពួកមារ ។

- ការត្រាស់ដឹងសម្រេចសម្មាសម្ពោធិញ្ញាណ

- ការសំដែងបឋមទេសនា ធម្មចក្រ

- ការបរិនិព្វាន ។ល។

# ពុទ្ធប្រវត្តិ

- ព្រះពុទ្ធជាមនុស្ស ឬត្រក្សត្រ កើតនៅប្រទេសណា ។

- ព្រះពុទ្ធប្រសូត នៅថ្ងៃសុក្រ ១៥ កើត ខែពិសាខ ឆ្នាំច មុន គ.ស ៦២៤ ឆ្នាំ ក្នុងឧទ្យានលុម្ពិនី ក្រុងកបិល-ពស្តុ ទ្រង់ព្រះនាមថា «សិទ្ធត្ថ» (អ្នកធ្វើឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង, សំ-សិទ្ធាថ) ក្នុងវង្ស គោតមៗ

- ព្រះបិតា ព្រះនាម សុទ្ធោទន, ព្រះមាតា ព្រះនាម សិរីមហាមាយា សោយរាជ្យនៅនគរកបិលពស្តុ (ប្រទេស នេប៉ាល សព្វថ្ងៃ) នាសតវត្សទី ៧ មុន គ.ស ។

- ព្រះសិទ្ធត្ថ បានសិក្សាវិជ្ជាផ្សេង ៗ ព្រមទាំងសិក្សារបៀបចប់គម្ពីរត្រៃវេទ តាមលទ្ធិព្រាហ្មណ៍កន្សំណាក់ព្រះគ្រូពិស្វាមិត្រ ។

- លុះព្រះជន្ម បាន ១៦វស្សា ទ្រង់បានរៀបអភិសេកជាមួយនឹងព្រះនាងពិមាយសោធរា (ដែលត្រូវជាបងប្អូនជីដូនមួយ បុត្រីស្តេចសុប្បពុទ្ធ) ។

- ព្រះសុទ្ធោទន៍ ជាបិតា បានឲ្យគេសង់ប្រាសាទ ៣ ថ្វាយព្រះសិទ្ធត្ថ តម្រូវទៅតាមរដូវទាំង ៣ : គឺ គេដាក់រាំហើយ ។

- ទ្រង់បានជួបប្រទះឃើញ មនុស្ស ៤ ពួក គឺមនុស្សចាស់ ឈឺ ស្លាប់ និងអ្នកបួស នៅពេលដែលព្រះអង្គបានយាងចេញអំពីវាំង ធ្វើទស្សនកិច្ច ជុំវិញទីក្រុង ។ មនុស្សទាំង ៤ ប្រភេទនេះ បានធ្វើឲ្យព្រះអង្គកើតសង្វេគយល់បញ្ហាជីវិត និងការឈឺចាប់ ទុក្ខវេទនា នៃមនុស្សសត្វ ។

- ព្រះសិទ្ធត្ថមានបុត្រមួយ នាមរាហុល ។

- លុះព្រះជន្មបាន ២៩វស្សា , ក្រោយដែលបានវិលត្រឡប់អំពីឧទ្យាន ដែលទ្រង់បានទតឃើញភិក្ខុអ្នកបួស អំពីថ្ងៃ, ពេលរាត្រីស្ងាត់ ព្រះសិទ្ធត្ថបានបោះបង់ចោលរាជសម្បត្តិ មហេសីនិងបុត្រ យាងចេញសាងផ្នួស ចម្ងាយផ្លូវ ៣០ យោជន៍ នៅអៀបឆ្នេរស្ទឹងអនោមានទី ក្នុងថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអាសាឍ ឆ្នាំថោះ ។

- លុះបួសរួច ព្រះអង្គបានទៅសិក្សារៀនសូត្រ ក្នុងសំណាក់តាបស ពីររូប ដែលបានសម្រេចឈានជាន់ខ្ពស់ គឺ ឧទកតាបស និង អាឡារតាបស តែពុំអាចរកឃើញនូវសច្ចធម៌ ដែលជាមាគ៌ារំលត់ទុក្ខសោះឡើយ ។ ម្លោះហើយ ព្រះអង្គចាំបាច់ត្រូវតែសុំលាតាបសទាំងពីររូប ចេញទៅស្វែងរកសិក្សា ស្រាវជ្រាវរាវរក តទៅទៀត នូវសច្ចធម៌ ។

– ព្រះអង្គបានខំប្រឹងព្យាយាម តស៊ូ ស្វែងរកមោក្ខ-ធម៌ មានការលត់ទុក្ខ ដោយធ្វើទុក្ករកិរិយា អស់រយៈកាល៦ឆ្នាំ លុះក្រោយតែទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណ ទើបដឹងយល់ ស្គាល់ សព្វគ្រប់ការពិតសព្វ ដែលហៅថា ត្រាស់ដឹង។

– ទ្រង់បានត្រាស់ដឹង ជាព្រះពុទ្ធ នៅថ្ងៃពុធ ១៥ កើត ខែវិសាខ ឆ្នាំរកា ក្នុងព្រះជន្មាយុ ៣៥ ឆ្នាំ (៥៨៩ ឆ្នាំមុន គ.ស) នៅក្រោមដើមពោធិព្រឹក្ស នារដ្ឋ ពិហារ សព្វថ្ងៃ ។

– ព្រះពុទ្ធបានយាងទៅទេសនា លើកទី ១ « បឋមទេសនា » មានឈ្មោះថា „ធម្មចក្រ ឬធម្មចក្កប្បវត្តនសូត្រ” ប្រោសភិក្ខុបញ្ចវគ្គីយ ចំនួន ៥ រូប, ដែលជាសហការីចាស់ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្បែរក្រុងពារាណសី ។

– ទ្រង់បានយាងទេសនា ប្រោស សត្វ ដោយពុំមាន ប្រកាន់ វណ្ណៈ ឋានៈ សោះឡើយ ជាពិសេស

7

ទ្រង់បានប្រកាសផ្សាយរំលាយ វណ្ណៈ ថែមទៀត ។

- ព្រះពុទ្ធ ទ្រង់ទេសនា ទូន្មាន ប្រៀនប្រដៅ មនុស្ស សត្វអស់រយៈកាល ៤៥ ឆ្នាំ មានពុទ្ធវចនៈ ទាំងអស់ ចំនួន ៨៤០០០ ធម្មក្ខន្ធ ។

- ព្រះពុទ្ធ បរិនិព្វាន ក្នុងព្រះជន្មាយុ ៨០ ឆ្នាំ គត់នៅ ថ្ងៃអង្គារ ១៥ កើតខែវិសាខ ឆ្នាំម្សាញ់ មុន គ.ស ៥៤៣ ឆ្នាំ ក្រោមដើមសាលព្រឹក្សទាំងគូ វេលាទៀបភ្លឺ នាក្រុងកុសិនារា ( សព្វថ្ងៃហៅឧត្តរប្រទេស ) ។

ចប់ពុទ្ធប្បវត្តិដោយសង្ខេប

*   *

*

# ពុទ្ធលទ្ធិ

ឬ

# ពុទ្ធសាសនា

ពុទ្ធលទ្ធិ ជាទស្សនៈ ទ្រឹស្តី របស់ព្រះពុទ្ធ កើតមានឡើងជាដំបូង នៅប្រទេសឥណ្ឌា ក្នុងសតវត្សទី ៦ មុនគ.ស មានគោលបញ្ញាប់សម្រាប់ប្រព្រឹត្តប្រតិបត្តិ ចំនួន ៨៤០០០ ធម្មក្ខន្ធដែលមានចារឹកក្នុងគម្ពីរព្រះត្រៃបិដក ។ បច្ចុប្បន្ននេះ អ្នកដែលគោរពជឿកាន់ព្រះពុទ្ធសាសនា ហៅថា ពុទ្ធសាសនិក មានចំនួន ៥០០.០០០.០០០ នាក់ មាននៅក្នុងប្រទេស ខ្មែរ សៀម លាវ ចិន យួន ភូមា ឥណ្ឌា លង្កា នេប៉ាល់ ទីបេត៍ ជប៉ុន ម៉ុងហ្គោលី ។ល។

## ព្រះត្រៃបិដក

**Tripitaka**

ព្រះត្រៃបិដក ជាគម្ពីរ ដែលជាឃ្លាំងផ្ទុកនូវពុទ្ធវចនៈ ចំនួន ៨៤០០០ ធម្មក្ខន្ធ ចែកជាសៀវភៅបោះពុម្ព

នៅប្រទេសខ្មែរ មានចំនួន ១១០ ភាគ ហើយភាគនីមួយៗ មានចំនួនប្រមាណ ពី ២០០-៣០០-៤០០ ទំព័រ ជាភាសា បាលី - ខ្មែរ ។

ព្រះត្រៃបិដក ១១០ ភាគនោះគឺ :

១- វិនយបិដក មាន ១៣ភាគ មាន ២១០០០ធម្មក្ខន្ធ
២- សុត្តន្តបិដក មាន ៦៤ភាគ មាន ២១០០០ធម្មក្ខន្ធ
៣- អភិធម្មបិដក មាន ៣៣ភាគមាន ៤២០០០ធម្មក្ខន្ធ

រួម មាន ១១០ភាគមាន ៨៤០០០ធម្មក្ខន្ធ

ក-វិន័យបិដក : ជាគម្ពីរស្តីអំពីច្បាប់ ក្រិត្យក្រម ដែល ព្រះពុទ្ធទ្រង់បញ្ញត្ត ហាមប្រាម និងទ្រង់អនុញ្ញាតទុក សម្រាប់ជាគោលប្រព្រឹត្ត ប្រតិបត្តិ នៃបព្វជិត និងគ្រហស្ថ ដែលជាភិក្ខុ ភិក្ខុនី សាមណេរ សាមណេរី ឧបាសក ឧបាសិកា ទាយក ទាយិកា ។ គម្ពីរវិន័យបិដក ជាកញ្ចក់ សម្រាប់ឆ្លុះ មើល នូវជីវប្រវត្តិ ជីវភាព សកម្មភាព របស់ព្រះពុទ្ធ និង

ការអប់រំទូន្មាន ប្រៀនប្រដៅ ពុទ្ធបរិស័ទ និង សាវ័ក ដើម្បីផ្សាយសទ្ធម៌ ក្នុងពេលដែលព្រះអង្គគង់ព្រះជន្មាយុនៅឡើយ ។

មិនតែប៉ុណ្ណោះ គម្ពីរវិន័យបិដក ជាឯកសារមួយដ៏សំខាន់ដែលបានបង្ហាញ ព្រឹត្តិការណ៍ផ្សេង ១ ក្នុងប្រទេសឥណ្ឌា ដូចជា :

វិស័យគ្រប់គ្រងប្រទេស របៀបរស់នៅ ផ្នែកប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ សិល្បៈវិជ្ជាផ្សេង ១ ។ល។

វិន័យបិដក មាន ៥ គម្ពីរ គឺ :

- អាទិកម្ម ស្តីអំពីទោសធ្ងន់
- បាចិត្តិយៈ ស្តីអំពីទោសស្រាល
- មហាវគ្គ វគ្គធំ
- ចុល្លវគ្គ វគ្គតូច

- បរិវារ: បទបន្ទាប់បន្សំ, មាតិកាផ្សេងៗ

ខ - សុត្តន្តបិដក : ជាគម្ពីរស្ដីអំពីសូត្រ ឬ អត្ថបទធម៌ ដែលព្រះអង្គទ្រង់ទេសនា ពន្យល់ ប្រោសមនុស្សសត្វ ឲ្យប្រព្រឹត្តល្អស្គាល់ បុណ្យ បាប ល្អ អាក្រក់ ក្នុងសម័យកាលផ្សេងៗ ។ល។ ហើយទាំង មានសូត្រខ្លះ សាវ័កសំដែងប្រោស ពន្យល់ពួកបរិស័ទមានព្រះ សារីបុត្រ មោគ្គល្លានកានន្ទ ជាដើម ។

សុត្តន្តបិដក មាន ៥ គម្ពីរ គឺ:

- ទីឃនិកាយ សូត្រវែង ពិស្ដារ
- មជ្ឈិមនិកាយ សូត្រមធ្យម
- សំយុត្តនិកាយ សូត្រប្រហែលៗគ្នា
- អង្គុត្តរនិកាយ សូត្រដែលចែកជាពួកជាក្រុម
- ខុទ្ទកនិកាយ សូត្រខ្លី តូចតាចៗ

គ - អភិធម្មបិដក : ជាគម្ពីរស្ដីអំពីធម៌កាយ អត្ថនៃធម៌

ដ៏ជ្រាលជ្រៅ ល្អិតសុខុម ជាបរមត្ថវិជ្ជា បានផល់ទស្សនវិជ្ជាព្រះពុទ្ធសាសនា ដែលថែងអធិប្បាយ អំពីចិត្ត ចេតសិក រូប និព្វាន ។

អភិធម្មបិដក មាន ៧ គម្ពីរ គឺ:

- ធម្មសង្គណី បំណាត់របៀបធម៌
- វិភង្គ ចំណែកវែកធម៌
- កថាវត្ថុ បំណុំធម៌ដែលផ្ទុយគ្នា
- បុគ្គលបញ្ញត្តិ បញ្ញត្តិជា បុគ្គល
- ធាតុកថា វិភាគធាតុ
- យមកៈ ធម៌ជាគូ ៗ
- បដ្ឋានៈ ធម៌មានទំនាក់ទំនងគ្នា ។

## និកាយ ពុទ្ធសាសនា

ពុទ្ធសាសនា បែកចេញទៅជានិកាយផ្សេងៗ ក្រោយ

ពេលដែលព្រះពុទ្ធបរិនិព្វាន ប្រមាណជាង២០០ឆ្នាំ តែនិកាយ

ដែលធំ ៗ មាន២ គឺ:

- មហាយាន (ឧត្តរនិកាយ - អាចរិយវាទ)

- ហីនយាន (ទក្ខិណនិកាយ - ថេរវាទ) ។

## ១- មហាយាន (Grand véhicule) -

យានធំ ទូលាយអាចផ្ទុកមនុស្សសត្វបានច្រើនគ្នា ដឹកនាំឆ្ពោះទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ។ និកាយមហាយានមានន័យធូរស្រាល ស្មៀកខោ ពាក់អាវ ពណ៌លឿង ។ និកាយនេះ សង្កត់យ៉ាងខ្លាំង ឬ ឲ្យតម្លៃទៅលើការអប់រំចិត្ត។ និកាយមហាយាន គោរពតាមលទ្ធិអាចរិយវាទ គឺប្រព្រឹត្តប្រតិបត្តិតាមគ្រូអាចារ្យរបស់ខ្លួនគ ៗ គ្នា មិនប្រតិបត្តិតាមគោលព្រះត្រៃបិដក ដូចនិកាយហីនយាន ទេ ។ អ្នកប្រាជ្ញនៃនិកាយមហាយាន បានបង្កើតគម្ពីរដីកាប្លែកអំពីគម្ពីរព្រះត្រៃបិដកគឺ :

- គម្ពីរ សទ្ធម្មបុណ្ឌរីក

- គម្ពីរ លង្កាវតារសូត្រ

- គម្ពីរ ប្រាជ្ញាបារមិតា ជាដើម ហើយសុទ្ធតែ

បានកត់ជាអក្សរ ភាសា សំស្ក្រឹត ទាំងអស់ ។ និកាយនេះ លើកយកភាសា សំស្ក្រឹត ជាធំ ជាយានសម្រាប់សិក្សា ។ បច្ចុប្បន្ននេះ និកាយមហាយាន · មានឋិតនៅក្នុងប្រទេស ចិន យួន ជប៉ុន ទីបេត៍ ម៉ុងហ្គោលី ។ល។

និកាយមហាយានគោរព ពោធិសត្វ ៣ អង្គ គឺ:

១- អវលោកិតេស្វរ:

២- មញ្ជុស្រី

៣- មៃត្រីយ: ឬ ព្រះស្រីអារ្យមេត្រី ។

## ២- ហីនយាន (Petit vêhicule) -

យានតូចយានចង្អៀត ផ្ទុកមនុស្សសត្វបានតិច មានវិ-ន័យតឹងតែង មានការគោរពវិន័យយ៉ាងម៉ឺងម៉ាត់ ជាបឋម ជាធំៗ

និកាយនេះ ឲ្យតម្លៃទៅលើវិន័យ ការអប់រំខ្លួនខាងកាយ វាចា ចិត្តឲ្យបានល្អត្រឹមត្រូវ ស្រគត់ស្រគំ រម្យទម ៗ បព្វជិត គ្រងឃ្ញុំ ស្បង់ចីពរ ពណ៌លឿង ៗ និកាយហីនយាន គោរព ប្រព្រឹត្ត ប្រតិបត្តិតាមគម្ពីរព្រះត្រៃបិដក ដោយ យកភាសាបាលី ជាធំ ជាយាន ក្នុងការសិក្សា ពុទ្ធវចនៈ ៗ បច្ចុប្បន្ន ពុទ្ធសាសនានិកាយហីនយាន មាន ឋិតនៅប្រទេស : ខ្មែរ សៀម លាវ ភូមា លង្កា ឥណ្ឌា នេប៉ាល ។ល។ និកាយនេះ គោរព ព្រះពុទ្ធ តែមួយព្រះអង្គគឺ ព្រះសមណគោតម និង ព្រះធម៌ ព្រះសង្ឃ ។

* *

*

## គោលប្រតិបត្តិក្នុងពុទ្ធសាសនា

ពុទ្ធសាសនិក គ្រប់រូប ទាំងបព្វជិត ទាំងគ្រហស្ថ

គប្បីប្រព្រឹត្ត ប្រតិបត្តិ តាមគោលធំៗ ៣ យ៉ាង គឺ:

១– គោរព ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទុកជាត្រៃសរណគមន៍ ។

២– ព្យាយាម សិក្សា រៀនសូត្រ ពុទ្ធវចនៈ ធម៌វិន័យ ឲ្យបានចេះចាំពិតប្រាកដ ហើយប្រតិបត្តិតាម ដើម្បីបានជាមធ្យោបាយសាងខ្លួនឲ្យបានល្អ ។

៣– បំពេញ ទាន សីល សមាធិ បញ្ញា ដែលជាវិធី ឬ មាគ៌ា សម្រាំងទូន្មាន កាយ វាចា ចិត្ត ឲ្យបានល្អស្អាត ត្រឹមត្រូវ បរិសុទ្ធផូរផង់ ប្រាសចាក លោភៈ ទោសៈ មោហៈ ហើយដែលជាមធ្យោបាយរំដោះខ្លួន ឲ្យផុតចាកទុក្ខទាំងពួង ។

* * *

# បញ្ហា ពុទ្ធិ តាមៈ សុខៈ ក្នុងពុទ្ធសាសនា

## ក– ពុទ្ធិ– La connaissance :

ពុទ្ធិ គឺចំណេះចេះដឹង យល់ស្គាល់ កើតមកអំពីការសិក្សា ពិចារណា ។ ពុទ្ធិ អាចកើតមកអំពីការសិក្សាត្រិះរិះ ពិចារណា ការស្ដាប់ ការរៀន គិត ពិសោធ ។ល។ នៃមនុស្ស ។ ពុទ្ធិដ៏ខ្ពង់ខ្ពស់ ដ៏ប្រសើរ ហៅថា សម្មាសម្ពោធិ បានដល់វិជ្ជា ៣ ប្រការ គឺ :

១– បុព្វេនិវាសានុស្សតិវិជ្ជា វិជ្ជានាំឲ្យរឭកនឹកឃើញនូវជាតិកំណើតរបស់ខ្លួន និងអ្នកដទៃ ដែលបានកន្លងច្រើនជាតិ រួចមកហើយ ។

២– ចុតូបបាតវិជ្ជា វិជ្ជានាំឲ្យមើលឃើញ ដឹងយល់នូវបុព្វហេតុដែលនាំឲ្យមនុស្ស កើត ចាស់ ឈឺ ស្លាប់ និងការចាប់ជាតិកំណើតថ្មី ជានេះ ជានោះ ។

៣– អាសវក្ខយវិជ្ជា វិជ្ជានាំឲ្យដឹងច្បាស់នូវការរលត់

error, ignorance

អស់កិលេសតណ្ហា មានលោភៈ ទោសៈ មោហៈ ជាដើម ។

វិជ្ជាទាំង ៣ នេះ ហៅថា "ត្រៃវិជ្ជា=វិជ្ជា ៣" ។

ក្រោយដែលបានចេះពិតប្រាកដនូវវិជ្ជាទាំង ៣ នេះ សព្វគ្រប់ហើយ ព្រះពុទ្ធក៏បានរកឃើញនូវសច្ចធម៌ ៤ប្រការ ដែលហៅថា អរិយសច្ច ៤ គឺ :

១– ទុក្ខសច្ច ដឹងថានេះជាទុក្ខ ជាការពិត ។

២– សមុទយសច្ច ដឹងថា នេះជាហេតុនាំឲ្យកើតទុក្ខ នាំឲ្យមានទុក្ខ ជាការពិត ។

៣– មគ្គសច្ច ដឹងថា នេះជាមាគ៌ានាំឲ្យផុតទុក្ខនាំឲ្យអស់ទុក្ខ ជាការពិត ។

៤– និរោធសច្ច ដឹងថា នេះជាការរលត់ទុក្ខ ជាការពិត ។

ពុទ្ធិទាំងអស់នេះ ជាវិជ្ជាអាចកើតមានដោយសារការ

ព្យាយាម ចំរើនសន្សំ អប់រំ សិក្សារៀនសូត្រ រិះរក រិះគិត ពិចារណា របស់មនុស្ស បន្តិចម្តងៗ អស់កាលវេលា ជាយូរអង្វែងឆ្នាំ ហើយជាពុទ្ធិ ដែលតាមកើតមានចំពោះមនុស្សទូទៅ ពុំមានគិតអំពីជាតិកំណើត ឬវណ្ណៈឋានៈ នោះឡើយ ។

ខ- ភាវៈ **L'être** :

ភាវៈ គឺ ដី ទឹក ភ្លើង ខ្យល់ អាកាស លោកៈធម្មជាតិ រុក្ខជាតិ ចិត្ត មនុស្ស សត្វ លោកធាតុ ។ល។ ទាំងអស់នេះ សុទ្ធតែឋិតនៅក្រោមអំណាចច្បាប់ធម្មជាតិ ៣យ៉ាង ហៅថា ត្រៃលក្ខណ៍ លើកលែងតែនិព្វាន ។

# ត្រៃលក្ខណ៍

## ឬ

## លក្ខណៈ ៣ យ៉ាងនៃធម្មជាតិ

អ្វីទាំងអស់ក្នុងលោក ការៈគឺ ធម្មជាតិគឺ លោកៈគឺ មនុស្សសត្វគឺ សុទ្ធតែឋិតនៅក្នុង លក្ខណៈ ៣ យ៉ាងគឺៈ

១– អនិច្ចំ មិនទៀងទាត់ឋិតថេរ ។

២– ទុក្ខំ ជាទុក្ខលំបាកវេទនា ពិបាកនឹងទ្រាំទ្រ ។

៣– អនត្តា ពុំស្តាប់បង្គាប់ មិនមែនជារបស់ខ្លួន គ្មានអត្តៈ។

ការៈ ទាំងអស់កកើតឡើងឯង តាមធម្មជាតិ ចាប់តាំងអំពីធាតុតូច ៗ ល្អិត ដែលជាបរមាណូធាតុ ផ្គុំផ្សំគ្នា ជាសង្ខតៈ បង្កបង្កើត ជាធាតុ ដី ទឹក ភ្លើង ខ្យល់ អស់កាលយូរ ៗ ធាតុទាំងនេះ ផ្គុំផ្សំគ្នាជា សង្ខតធាតុ ក៏បង្កើតបានជារុក្ខជាតិ ជាសត្វ ជាមនុស្ស ជាទេវតា ជាដើម ។ ការៈ ទាំងអស់ កើតមានឡើង ដោយសារទំ

នាក់ទំនងនៃសន្តតធាតុ ហើយបាននៅជា សង្ខារ ។

ឯនិព្វាន ជាទីរលត់ទុក្ខ ផុតទុក្ខ ព្រោះឃាតសង្ខារ ការតាក់តែង មានតែសេចក្ដីសុខដ៏បរិសុទ្ធ ។ កាលបើគ្មានសង្ខារ តាក់តែង, ព្រះនិព្វាន ក៏គ្មានរូប កាលបើគ្មានរូប ព្រះនិព្វានក៏ត្រូវបិតនៅក្រៅអំណាច ច្បាប់ធម្មជាតិដែលជាត្រៃលក្ខណ៍ ។ បានសេចក្ដីថា ព្រះនិព្វាន គ្មានការកើត ចាស់ ឈឺ ស្លាប់ គ្មានទុក្ខ ផុតចាកទុក្ខទាំងពួង មានតែនិរាមិសសុខ ជាបរមសុខតែម្យ៉ាង ។

គ- សុខ: **Le Bonheur** :

សុខ: សេចក្ដីសុខសប្បាយរីករាយ ត្រជាក់ចិត្ត ស្រួលកាយ មាន ២ យ៉ាង គឺ:

១- លោកិយសុខ សុខក្នុងលោកិយ លាយឡំដោយទុក្ខ ។

២- បរមសុខ សុខដ៏បរិសុទ្ធ ដ៏ប្រសើរ គ្មាន

ណាយទៀងដោយទុក្ខ គឺព្រះនិព្វានៗ

សេចក្តីសុខ ទាំងពីរប្រភេទនេះ តែងតែកើតមាន ឡើងដោយឥទ្ធិពលនៃការកសាងសន្សំ ធ្វើបុណ្យ ធ្វើល្អ ខំប្រឹងព្យាយាមស្វែងរកបក្ខពួកៗ នៃមនុស្ស សត្វ ពល់រូបៗ

៦. គោលបំណងធំបំផុត នៃពុទ្ធលទ្ធិ គឺការរលាស់ខ្លួនចេញឲ្យផុតអំពីទុក្ខ ក្នុងសង្សារវដ្ត ហើយបាញ់ឆ្ពោះទៅបរមសុខ គឺព្រះនិព្វាន ។ ដើម្បីនឹងបានសម្រេចបរមសុខ មនុស្សត្រូវដើរតាមមាគ៌ា មជ្ឈិមាបដិបទា ៨ ប្រការ គឺ:

- សម្មាទិដ្ឋិ យល់ក្នុងផ្លូវត្រូវ (យល់ត្រូវ)
- សម្មាសង្កប្បៈ ត្រិះរិះក្នុងផ្លូវត្រូវ (ត្រិះរិះត្រូវ)
- សម្មាវាចា និយាយក្នុងផ្លូវត្រូវ (និយាយត្រូវ)
- សម្មាកម្មន្តៈ ប្រកបការងារក្នុងផ្លូវត្រូវ (ការងារត្រូវ)
- សម្មាអាជីវៈ ចិញ្ចឹមជីវិតក្នុងផ្លូវត្រូវ (ចិញ្ចឹមជីវិត

(ត្រូវ)

− សម្មាវាយាមៈ ព្យាយាមក្នុងផ្លូវត្រូវ (ព្យាយាមត្រូវ)

− សម្មាសតិ ភ្ញាក់រឭកក្នុងផ្លូវត្រូវ (រលឹកត្រូវ)

− សម្មាសមាធិ តម្កល់ចិត្តក្នុងផ្លូវត្រូវ (តម្កល់ចិត្តត្រូវ)

ដែលរួម បានដល់ សីល សមាធិ បញ្ញា ។

## កម្ម− Action

កម្ម គឺ អំពើ កិច្ចការ ការងារ ដែលបុគ្គលមួយរូប ១ បានធ្វើ បានប្រព្រឹត្ត ដោយកាយ វាចា ចិត្ត ។

កម្មនេះមាន ២ យ៉ាង គឺ :

១− កម្មល្អ អំពើល្អ គឺ កុសលកម្ម បុណ្យ ។

២− កម្មអាក្រក់ អំពើអាក្រក់ គឺ បាបកម្ម បាប ។

កម្មទាំងពីរយ៉ាង តែងកើតមានឡើងគ្រប់ពេលវេលា ដោយសារការប្រព្រឹត្ត ការធ្វើ របស់មនុស្សម្នាក់ ៗ ពោលគឺ មនុស្សជាអ្នកសាងកម្មនេះដោយខ្លួនឯង ហើយ

ត្រូវទទួលយកខ្លួនឯងនូវផលនៃកម្មនេះ ។ កម្មទាំងពីរនេះ អាចផ្តល់ផលជា ២ បែប គឺ :

១– ផលកើតចេញមកអំពីកម្ម ក្នុងបច្ចុប្បន្នជាតិនេះ។

២– ផលកើតចេញមកអំពីកម្ម ក្នុងអតីតជាតិ ។

កម្មខ្លះ អំពើខ្លះ រមែងផ្តល់ផល ហុចផលភ្លាម ៗ ក្នុងបច្ចុប្បន្ន ។ កម្មខ្លះ អំពើខ្លះ រមែងហុចផល ឲ្យអ្នកធ្វើ អ្នកប្រព្រឹត្ត នៅពេលខាងក្រោយដ៏យូរ ឬ ក្នុងអនាគត ។

កម្មនេះ ជាសម្បត្តិផ្ទាល់របស់មនុស្សម្នាក់ ៗ ។ កម្មនេះតែងតែចែកមនុស្សសត្វ ឲ្យខុសគ្នា ល្អ អាក្រក់ ស ខ្មៅ តម្រូវតាមការកសាង ឬ អំពើរបស់មនុស្សម្នាក់ៗ ។ គេសាបព្រួសបណ្តុះពូជបែបណា រមែងទទួលផលបែបនោះ ។ អ្នកធ្វើអំពើល្អ កម្មល្អ រមែងទទួលផលល្អ គឺផលបុណ្យ ។ ឯអ្នកធ្វើអំពើអាក្រក់ រមែងទទួលផល

អាក្រក់ គឺផលបាប ។ ធ្វើល្អ បានល្អ ធ្វើអាក្រក់បាន អាក្រក់ ។ កម្មស ឲ្យផលស កម្មខ្មៅ ឲ្យផលខ្មៅ ។ ខ្លួនទីពឹងខ្លួន សេចក្ដីបរិសុទ្ធ និងមិនបរិសុទ្ធ ស្រេចតែខ្លួនឯង គ្មានអ្នកដទៃណា មកសាងឬ ទទួលជំនួសខ្លួនឡើយ ។ កម្មស អំពើល្អ ផ្ដល់ផលឲ្យមានសុខសប្បាយ ។ កម្មខ្មៅ អំពើអាក្រក់ ផ្ដល់ផលឲ្យបានទុក្ខលំបាកវេទនា ។

ហេតុនេះ ដើម្បីឲ្យបានសេចក្ដីសុខសប្បាយរីករាយ មានជោគជ័យ និងសុភមង្គល គប្បីនាំគ្នាខំសាង ខំធ្វើអំពើល្អ អំពើបុណ្យ ឲ្យបានច្រើន ព្រោះអំពើល្អនេះជាពូជ សម្រាប់ផ្ដែរបនាយើងម្នាក់ ៗ ឲ្យបានខ្ពង់ខ្ពស់ ថ្លៃថ្នូរ សុខសប្បាយគ្រប់ពេលវេលាតាំង អំពីបច្ចុប្បន្ន រហូតដល់អនាគត ។

* *

# អរិយសច្ច ៤

## Les 4 nobles verités

អរិយសច្ចៈ សច្ចៈដ៏ប្រសើរខ្ពង់ខ្ពស់ ឬ សេចក្ដីពិតដ៏ប្រសើរ ដែលព្រះពុទ្ធបានខំព្យាយាមស្វែងរក ស្រាវជ្រាវការរកឃើញ គឺចតុរិយសច្ច ។

- ទុក្ខសច្ច
- សមុទយសច្ច
- និរោធសច្ច
- មគ្គសច្ច

១– ទុក្ខសច្ចៈ : គឺទុក្ខជាសេចក្ដីពិត ដែលកើតមានដល់រូបកាយមនុស្សសត្វ គ្រប់រូប មាន ១៣ ករណី :

- ជាតិទុក្ខ ទុក្ខកើតពីការកើត ។
- ជរាទុក្ខ ទុក្ខកើតពីចាស់គ្រាំគ្រាទ្រុឌទ្រោម ។
- ព្យាធិទុក្ខ ទុក្ខកើតអំពីជំងឺរោគាផ្សេងៗ ។
- មរណទុក្ខ ទុក្ខកើតពីមរណភាព ។
- សោកទុក្ខ ទុក្ខកើតពីការយំសោក ។

– ជរាទុក្ខ ទុក្ខកើតពីការទ្រុឌទ្រុល ។

– ទុក្ខទុក្ខ ទុក្ខត្រួតលើទុក្ខ - ទុញគិនិត ។

– ទោមនស្សទុក្ខ ទុក្ខកើតពីខឹងក្រោធ តួបចិត្ត ។

– ឧបាយាសទុក្ខ ទុក្ខកើតពីបង្អៀតចិត្ត ។

– អប្បិយសម្បយោគទុក្ខ ទុក្ខកើតពីការជួបប្រទះវត្ថុសប់ណាង ។

– បិយវិប្បយោគទុក្ខ ទុក្ខកើតពីការព្រាត់ប្រាសវត្ថុស្រឡាញ់ ។

– យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ទុក្ខកើតពីមិនបានដូចប្រាថ្នា ។

– សង្ខិតបញ្ចុប្បាទានក្ខន្ធទុក្ខ ទុក្ខកើតពីខន្ធ ៥ ។

ទុក្ខសច្ច មាន អត្ថ ៥ ប្រការ គឺៈ

១– បីឡនៈ ចៀតចៀន ។

២– សំខតៈ ផ្គុំផ្សំតាក់តែង ។

៣- សន្តាប: ក្តៅក្រហាយ ។

៤- វិបរិណាម: ប្រែប្រួល ។

២- សមុទយសច្ច: ហេតុដែលនាំឲ្យកើតទុក្ខមាន

ទុក្ខ ជាសេចក្តីពិត បានដល់ តណ្ហា ៣ ប្រការ

(3 Désirs) គឺ:

១- កាមតណ្ហា ចំណង់ក្នុងកាមគុណ ។

២- ភវតណ្ហា ចំណង់ក្នុងការកើតក្នុងភពមានរូប

និងអរូប ។

៣- វិភវតណ្ហា ចំណង់ក្នុងការកើតក្នុងភពសូន្យ ។

តណ្ហា មានដើមកំណើតកើតចេញមកអំពីខន្ធ ៥ គឺ:

ក) រូបខន្ធ Agrégat de la matière

ខ) វេទនាខន្ធ Agrégat des sensations

គ) សញ្ញាខន្ធ Agrégat des perceptions

ឃ) សង្ខារខន្ធ Agrégat des formations

ង) វិញ្ញាណខន្ធ Agrégat de la conscience

ក- រូបខន្ធ : ការប្រជុំធាតុ គឺ រូប ។ រូប កើតមក អំពីការផ្សំផ្គុំធាតុ ៤ គឺ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ "ដី ទឹក ភ្លើង ខ្យល់" ជាមហាភូតរូប ៤ ហើយនឹង ឧបាទាយរូប ២៤ ដែលមានឥន្ទ្រិយ ៥ ជាដើម ។

ខ- វេទនាខន្ធ : ការប្រជុំធាតុ គឺ វេទនា ។ វេទនា ការទទួល ឬ សោយនូវអារម្មណ៍ផ្សេងៗ ដែលកើតឡើង អំពី :

- ចិត្តរំភើបញាប់ញ័រ (ចិត្តវេគ Emotion)
- ចិត្តរំជួល (មនោសញ្ចេតនា Sentiment)
- ចិត្តជំទក់ជាប់ជំពាក់ (កិលេស Passion) ។

វេទនា មានកំណត់កំណើតអំពី ផស្សៈ ការប៉ះទង្គិច រវាងឥន្ទ្រិយ និង វត្ថុអារម្មណ៍ ដែលអាចបង្កើតជាឥន្ទ្រិយារម្មណ៍ គឺ :

ចក្ខុ - ចក្ខុន្ទ្រិយ បង្កើតបានជា រូបារម្មណ៍

សោត- សោតិន្ទ្រិយ „ សទ្ទារម្មណ៍

ឃាន - ឃានិន្ទ្រិយ „ គន្ធារម្មណ៍

កាយ - កាយិន្ទ្រិយ „ ផោដ្ឋព្វារម្មណ៍

ជិវ្ហា - ជិវ្ហិន្ទ្រិយ „ រសារម្មណ៍

មនៈ - មនិន្ទ្រិយ „ ធម្មារម្មណ៍ ។

គ- សញ្ញាខន្ធ : ការប្រជុំធាតុ គឺសញ្ញា ។ សញ្ញា គឺការកំណត់ចំណាំ សំគាល់នូវតែអារម្មណ៍ ។ សញ្ញាអាច កើតឡើងដោយសារ ការដឹង ឃើញ យល់ ស្គាល់ នូវ អារម្មណ៍ផ្សេង ៗ តាមរយៈ អាយតនៈ មិនតែអារម្មណ៍ ។

ឃ- សង្ខារខន្ធ : ការប្រជុំធាតុ គឺសង្ខារ ។ សង្ខារ គឺ ការផ្សំ ការតុបតែង ផ្គុំផ្គុំ ចងជាកម្រង ។ សង្ខារ មានប្រភពកើតមកអំពីកម្ម ។ កម្ម កើតមកអំពីចេតនា ។

សកម្មភាព នៃ ចេតនា គឺ :

- ឆន្ទៈ Volonté
- វីរិយៈ Energie , effort
- មនសិការ Attention
- អធិមោក្ខ Détermination
- សទ្ធា Confiance
- សមាធិ Concentration
- បញ្ញា Sagesse
- រាគៈ Désir
- បដិឃៈ Répulsion , haine
- មានៈ Vanité
- អវិជ្ជា Ignorance
- សក្កាយទិដ្ឋិ Idée du soi ។ល។

សកម្មភាពនៃវេទនា ទាំងនេះ គឺជា កម្មវិបាក ដោយបានបង្កបង្កើត ជា សង្ខារ ។

ង~ វិញ្ញាណខន្ធ : ការប្រជុំធាតុ គឺ វិញ្ញាណ ។ វិញ្ញាណ គឺ គ្រឿងដឹង ការដឹងនូវអារម្មណ៍ផ្សេងៗ ឬ វិញ្ញាណ គឺ ជាប្រតិកម្ម ឬ ជាចម្លើយមួយ នៃឥន្ទ្រិយ ឬគឺ វិញ្ញាណ ជា សមត្ថភាព ដែលនាំឲ្យយើង ដឹង យល់ ស្គាល់ នូវលោកខាងក្រៅ និងខ្លួនឯង ដោយសារការប៉ះ ទង្គិចរវាងឥន្ទ្រិយ និង វត្ថអារម្មណ៍ ។

សមុទយសច្ច មានអត្ថ ៤ ប្រការគឺ:

១- អាយុហន: ការប្រមូលមក

២- និទាន: ជាហេតុ

៣- សំយោគ: ប្រកបព្រម

៤- ពលិពោធ: កង្វល់ ។

៣~ និរោធសច្ច — ការរលត់ទុក្ខ រួចចាកទុក្ខ ជាសេចក្តីពិត ។ និរោធ: ការរលត់ ការរួចស្រឡះ ការបានឥស្សរភាព គឺ ខំព្យាម បានផល :

- ការអស់ចំណង់រលីង

- ការរលត់តណ្ហា និងកិលេសគ្រប់យ៉ាង

- ការរលាស់ចេញផុត រួចស្រឡះចាកទុក្ខទាំងពួង ៗលៗ ហៅថា និព្វាន មាន ២ យ៉ាង គឺ:

១- សឧបាទិសេសនិព្វាន ការរលត់កិលេសតណ្ហា ទាំងអស់នៅសល់តែខន្ធ ៥ គឺ និព្វានរស់ ៗ

២- អនុបាទិសេសនិព្វាន ការរលត់កិលេសតណ្ហា និងខន្ធ៥ គឺនិព្វានស្លាប់ ៗ

និរោធសច្ច មានអត្ថ ៥ ប្រការ គឺ :

១- និស្សរណៈ: រខ្មួនចេញចាកភព

២- អបលោភៈ: គ្មានកង្វល់

៣- អសង្ខត: គ្មានបច្ច័យតាក់តែង

៤- អមតៈ: មិនចេះស្លាប់ ៗ

៥- មគ្គសច្ច មាគ៌ា ឬ មធ្យោបាយ នាំឲ្យផុតទុក្ខ

ជាសេចក្ដីពិតបានដល់មជ្ឈិមាបដិបទា មាគ៌ាកណ្ដាល មាន

អង្គ ៨ គឺ:

– សម្មាទិដ្ឋិ យល់ត្រូវ Compréhension juste

– សម្មាសង្កប្ប: ត្រិះរិះត្រូវ Penseé juste

– សម្មាវាចា និយាយត្រូវ Parole juste

– សម្មាកម្មន្ត ការងារត្រូវ Action juste

– សម្មាអាជីវ: ចិញ្ចឹមជីវិតត្រូវ Moyen d'existence juste

– សម្មាវាយាម: ព្យាយាមត្រូវ Effort juste

– សម្មាសតិ ភ្ញាក់រលឹកត្រូវ Attention juste

– សម្មាសមាធិ តម្កល់ចិត្តត្រូវ Concentration juste

មាគ៌ា ប្រកបដោយ អង្គ ៨ខាងលើនេះរួមបានដល់:

– សីល Conduite Ethique

– សមាធិ Discipline mentale

- បញ្ញា Sagesse

មគ្គសច្ច មានអត្ថ ៤ ប្រការ គឺ :-

១— និយ្យានៈ នាំខ្លួនចេញចាកភព

២— ហេតុ ជាហេតុ

៣— ទស្សនៈ សំដែងចេញ

៤— អធិបតិ អធិបតិ , ជាធំ ៗ

* *

*

# ទ្រឹស្តី បដិច្ចសមុប្បាទ

ឬ

# ធម៌ភាពភ្ជាប់ ហេតុទៅនឹងផល

**Loi de la causalité**

ទ្រឹស្តីបដិច្ចសមុប្បាទ ឬ ធម៌ភាពភ្ជាប់ហេតុទៅនឹងផល

មាន ១២ កត្តា គឺ :

១- អវិជ្ជា ignorance នាំឲ្យកើតសង្ខារ

២- សង្ខារ formation នាំឲ្យកើតវិញ្ញាណ

៣- វិញ្ញាណ conscience នាំឲ្យកើត នាមរូប

៤- នាមរូប Mentalité et Physique នាំឲ្យកើត អាយតនៈ ៦

៥- អាយតនៈ Sens នាំឲ្យកើតផស្សៈ

៦- ផស្សៈ Contact នាំឲ្យកើត វេទនា

៧- វេទនា Sensation នាំឲ្យកើត តណ្ហា

៨- តណ្ហា Désir នាំឲ្យកើតឧបាទាន

៩- ឧបាទាន Saisie នាំឲ្យកើត ភព

១០- ភព Processus du devenir " ជាតិ

១១- ជាតិ Naissance " ជរា ព្យាធិ មរណៈ

១២- ជរា ព្យាធិ មរណៈ នាំឲ្យមានអវិជ្ជា ។ល។

ទ្រឹស្តីបដិច្ចសមុប្បាទ ជាទ្រឹស្តីស្វែងរកការពិត នៃធម្ម-

ជាតិ មនុស្ស សត្វ ដោយការសិក្សា ពិចារណា ភ្ជាប់ហេតុ ទៅនឹងផលដូចជា :

បើនេះមាន  នោះក៏មាន

បើនេះគ្មាន  នោះក៏គ្មាន

បើនេះស្លាប់  នោះក៏ស្លាប់

បើនេះកើត  នោះក៏កើត ។ល។

ដូច្នេះកំណើត ការៈ ទាំងអស់ : មនុស្ស សត្វ លោកៈ ធម្មជាតិ ។ល។ សុទ្ធតែកកើតឡើង ដោយមានបច្ច័យ មានទំនាក់ទំនងស្រោស្រង់គ្នាទៅវិញទៅមក ចងភ្ជាប់គ្នាជាកម្រង ឬ ជារង្វង់មូល ដូចកង់ចក្រ ដែលត្រូវតែវិលជាចិច្ចវិលចុះវិលឡើង មួងលើ មួងក្រោម ពុំមានឈប់ឈរ សោះឡើយ ដោយមានអវិជ្ជា ជាមេ ជាប្រធាន ។

* * *

# ពុទ្ធសាសនា និង សង្គមខ្មែរ

ឥឡូវពេល ពុទ្ធសាសនា បានចាក់គ្រឹះយ៉ាងមាំ ក្នុងចិត្ត គំនិតខ្មែរ សង្គមខ្មែរ ចំពោះខ្មែរ មនោគមខ្មែរ តាំងពីយូរអង្វែងណាស់មកហើយ ៗ មានវត្តអារាម ជាច្រើន ប្រកបទៅដោយវិហារ កុដិ សាលា ដ៏ល្អ ៗ ជាច្រើនដែលពុទ្ធបរិស័ទ មានសទ្ធាជ្រះថ្លា បានកសាង ធ្វើជាសេនាសនៈ សំរាប់ព្រះសង្ឃគង់នៅ ដែលនិមន្តមកអំពីទិសទាំង ៤ និងជាទីសំរាប់ធ្វើបុណ្យសុន្ទរទាន ស្មាទាន រក្សាសីល ជាដើម ។ ប្រជាជនខ្មែរ ទាំងប្រុស ទាំងស្រី ភាគច្រើន ច្រើនតែជាឧបាសក ឧបាសិកា អ្នកកាន់ពុទ្ធសាសនា ធ្វើបុណ្យឲ្យទាន រក្សាសីល ៥ សីល ៨ សីល ១០ ធ្វើសមាធិកម្មដ្ឋានជាដើម ។ កាលសម័យបុរាណ ក្មេង ៗ កូនចៅ អ្នកស្រុក តែងបានចូលទៅសិក្សារៀនសូត្រ អក្សរសាស្ត្រ ធម្មសាស្ត្រ សិល្បៈ គុណធម៌ គុណធារ ជាដើម នៅក្នុងវត្ត

អារាម ដែលមានព្រះសង្ឃជាគ្រូបាធ្យាយ ។ អ្នកខ្លះ ក៏បានសុំផ្នួសបួសជាសាមណេរ ឬជាភិក្ខុ សិក្សា រៀនសូត្រធម៌អាថ៌ ក្នុងព្រះពុទ្ធសាសនា ។

ជាពិសេស ឥទ្ធិពលពុទ្ធសាសនា បានចូលស៊ុបសួន ចាក់ឫសយ៉ាងមាំ ក្នុងសង្គមខ្មែរ ទំនោរខ្មែរ ព្រលឹងខ្មែរ មនោគមខ្មែរ តាំងតែពីព្រេងសតវត្សណាស់មកហើយ ដែលមានជាអាទិ ក្នុង:

- ជំនឿ Croyance

ប្រពៃណី ទំនៀមទម្លាប់ Coutume - Mœurs

- សិល្ប: Art
- អក្សរសិល្ប៍ Littérature

## ក - ជំនឿ Croyance

ឥទ្ធិពល ពុទ្ធសាសនា បានបណ្ដាល បង្កើតឲ្យមាន

- ជំនឿ បុណ្យ បាប ។
- ជំនឿ កម្ម ផល ។

- ជំនឿ សច្ចៈ សុចរិត យុត្តិធម៌ ។
- ជំនឿ ស្ថានសួគ៌ ស្ថាននរក ។ល។

ដែលបានជាកត្តាដ៏ធំមួយ ជួយរុញច្រានសង្គមខ្មែរ មនុស្សខ្មែរ ឲ្យមាន សីលធម៌ មនុស្សធម៌ ស្គាល់បុណ្យបាប ហើយខំប្រឹងធ្វើ ខំប្រឹងកសាងអំពើល្អ គ្រប់ៗគ្នា ។

## ខ- ប្រពៃណី ទំនៀមទម្លាប់

**Coutume · Mœurs**

មានប្រពៃណី ទំនៀមទម្លាប់ ជាច្រើន ស្ទើរតែគ្រប់មែកធាងនៃ វប្បធម៌ អរិយធម៌ សុទ្ធតែមានទំនាក់ទំនងនឹងពុទ្ធសាសនា ដូចជា :

- ពិធីចំរើនជន្មាយុ (ចំរើនអាយុ)
- ពិធីអាពាហ៍ពិពាហ៍
- ពិធីបូជាសព ហែសព

- ពិធីគោរជុក ។
- ពិធី អភិសេក ព្រះពុទ្ធរូប ។

និងមានប្រពៃណីខ្លះទៀត ជាបែបពុទ្ធសាសនាសុទ្ធៗ ដូចជា :

- ពិធីចូលវស្សា
- ពិធីចេញវស្សា
- ពិធីបុណ្យកឋិន
- ពិធីបុណ្យផ្កា
- ពិធីភ្ជុំបិណ្ឌ
- ពិធីបុណ្យបច្ច័យ ៤
- ពិធីបុណ្យធាក មហាបង្សុកូល
- ពិធីបុណ្យ ទេសនាមហាជាតក៍ ។ល។

ប៉ុន្តែ ដោយហេតុថា ខ្មែរបានទទួលឥទ្ធិពលសាស-នាព្រាហ្មណ៍ផង ពុទ្ធសាសនាផង ម៉្លោះហើយក៏ប្រពៃណី

ទំនៀមទម្លាប់ខ្មែរ ក៏មានលាយបម្រុះ ដោយកត្តាទាំងពីរ ព្រាហ្មណ៍និយម ពុទ្ធនិយម ជាមួយនឹងខ្មែរនិយម ។

ហេតុនេះ ពិធីបុណ្យទានផ្សេង ៗ ដែលជាប្រពៃណី ច្រើនតែមានធាតុទាំង ៣ លាយគ្នាដូចជា:

– ពិធីបុណ្យចំរើនបរិត្ត : គេនិមន្តព្រះសង្ឃចំរើន បរិត្តផង ធ្វើស្លាធ័រ បាយសី ឬ ស្លាធ័រដូង ផង តាមបែប បុរាណ ។

– ពិធីស្រោចទឹករំដោះគ្រោះ : គេនិមន្តព្រះសង្ឃ សូត្រមន្តផង ធ្វើពិធីរំដោះគ្រោះ (បែបព្រាហ្មណ៍ មានសែន ព្រេន ជាដើម) ផង ។

ហេតុនេះ យើងអាចសន្និដ្ឋានថា : ប្រពៃណីណា ទំនៀមទម្លាប់ណា ដែលគេធ្វើហើយមានតម្កល់ព្រះពុទ្ធរូប ជាទីសក្ការបូជា មានចំរើនបរិត្ត ទេសនាជាដើម ទាំងអស់នេះ គឺជា បែបពុទ្ធនិយមក្នុងប្រពៃណី ទំនៀមទម្លាប់ខ្មែរ ។

## គ- សិល្បៈ L'art

### ១- គំនូរ - ចម្លាក់:

មានគំនូរ ចម្លាក់ជាច្រើន ដែលគេគូរឆ្លាក់យកលំនាំតាមជីវប្រវត្តិ និងសកម្មភាពព្រះពុទ្ធ ដូចជា :

- ការប្រសូត - ការឡើងសោយរាជ្យ
- ការចេញបួស - ការធ្វើទុក្ករកិរិយា
- ការផ្ចាញ់មារ - ការត្រាស់ដឹង
- ការសំដែងធម្មចក្រ - ការបរិនិព្វាន ។ល។

គំនូរ ចម្លាក់ខ្លះ គេគូរឆ្លាក់ ជាបដិមាករ តាមបែបមុទ្រ: គឺ :

ក) ធ្យានមុទ្រ: ព្រះពុទ្ធធ្វើឈាន : រូបគង់ពែនភ្នែនព្រះហស្តលាតាំងពីរ ដាក់ត្រួតលើគ្នា នៅលើភ្នែន ។

ខ) ភូមិស្បស៌មុទ្រ : - ព្រះពុទ្ធផ្ចាញ់មារ : រូបគង់ពែនភ្នែន ព្រះហស្តឆ្វេងដាក់ផ្ងារលើភ្លៅឆ្វេង, ព្រះហស្តស្តាំ

ដាក់លើភ្លៅស្តាំ មានចុងម្រាមដៃចង្អុលទៅរកផែនដី ។

គ) អភយមុទ្រ: ព្រះពុទ្ធឲ្យអភ័យដល់មនុស្សសត្វ : រូបឈរ លាបាតដៃទាំងពីរទៅមុខ ចុងម្រាមដៃឡើងលើទាំងអស់ ។

ឃ) ធម្មចក្រមុទ្រ: — ព្រះពុទ្ធសំដែងធម្មចក្រ : រូបគង់តែងខ្វែនក៏មាន គង់សំយុងជើងក៏មាន ដៃទាំងពីរដាក់លើទ្រូង ធ្វើដូចដាក់កង់ចក្រ ។

ង) វរមុទ្រ: — ព្រះពុទ្ធប្រទានពរ : រូបឈរ លាបាតដៃទាំងពីរទៅមុខ ម្រាមសំយុងចុះ ។

ច) បាត្រទានមុទ្រ: — ព្រះពុទ្ធទ្រង់បាត្រ : រូបឈរ ដៃទាំងពីរទ្របាត្រ ។

ឆ) វិតក្កមុទ្រ: — ព្រះពុទ្ធត្រិះរិះពិចារណា : រូបឈរ លាបាតដៃទាំងពីរទៅមុខ បត់ម្រាមកណ្ដាលជារង្វង់ភ្ជាប់នឹងមេដៃ ។

ង) ទុក្ករកិរិយាមុទ្រ: - ព្រះពុទ្ធធ្វើទុក្ករកិរិយា : រូបគង់ពែនភ្នែន ឬ ផ្ទុំ មានរូបកាយស្គាំងស្គម ឃើញតែឆ្អឹង ។

ឈ) សយនាមុទ្រ: - ព្រះពុទ្ធផ្ទុំ ឬ បរិនិព្វាន ។

**សង្កេត** :

លក្ខណៈពិសេស នៃកាយវិការ ថៃបមុទ្រ: ក្នុងសិល្បៈខ្មែរគួរកត់សំគាល់ គឺ:

១- ទឹកព្រះភក្ត្រញញឹមជាដរាប ហាក់ដូចជាគេឃើញនូវភាពចិត្តបាំងអ្វីមួយ ដ៏ជ្រាលជ្រៅ ។

២- ទ្រង់គង់ពែនភ្នែនលើបល្ល័ង្ក ឬ លើផ្កាឈូក ត្រង់ឬយុំបីតរ ។

៣- បំកណ្តាលព្រះសិរ: មានកំពូលមោលី ហើយមានកេសាវេញៗ ប្រទាក់គ្នាដូចខ្យងខ្ចៅ ឬ ដូចបន្លាសំបកខ្នុរ

៤- ព្រះកាណ៌ (ត្រចៀក) វែងនិងមានចញ្ចាណធ្លាក់ចេញអំពីព្រះសិរ: ដូចរស្មីព្រះអាទិត្យ ។

## ២- ប្រាសាទ Ruines :

នៅប្រទេសខ្មែរ មានប្រាសាទថ្ម ជាច្រើន ដែល គេសង់សាងឧទ្ទិសថ្វាយពុទ្ធសាសនា គឺ:

- ប្រាសាទ តាយ័ន មុនសតវត្សទី ១២នៃ គ.ស
- ប្រាសាទ តាព្រហ្ម គ.ស ១១៨៦
- ប្រាសាទ ព្រះខ័ន គ.ស ១១៩១
- ប្រាសាទ នាគព័ន្ធ ដើមពាក់កណ្ដាលសតវត្ស ទី ១២
- ប្រាសាទ បន្ទាយក្ដី
- ប្រាសាទ បន្ទាយឆ្មារ ។ល។

**ចំណាំ:** ការសង់ប្រាសាទតាមបែបពុទ្ធសាសនា ជាពុទ្ធនិយមគេច្រើនសង់នៅលើទីដីរាបស្មើ ពុំសូវមានជាន់ ថ្នាក់ខ្ពស់ៗ ដូចជាប្រាសាទបែបព្រាហ្មណ៍និយមទេ ។ ការណ៍នេះបញ្ជាក់ប្រាប់ឲ្យដឹងថា : ព្រះពុទ្ធជាមនុស្សប្រិត

នៅលើលោកនេះជាមួយនឹងមនុស្សគ្រប់គ្នាដែរទៀត គឺ ព្រះពុទ្ធពុំមែនរស់នៅលើមេឃ ដាច់ឆ្ងាយអំពីមនុស្សដូចជាទេវតា នៃសាសនាព្រាហ្មណ៍ទេ ។

ប៉ុន្តែ ព្រះពុទ្ធជាមនុស្សភ្ញាក់រឭកមុនគេ មានការតស៊ូព្យាយាម រើបំរះ ដោះខ្លួន ឲ្យរួចផុតអំពីទុក្ខ និងបញ្ហាធម្មជាតិ ។

## ៣- ស្តូប Stupa

[illegible] សំណង់តម្កល់អដ្ឋិធាតុ នៃមនុស្សដែល [illegible] បដបលោកតែមកក [illegible] [illegible] រង្វង់មូល (រង្វង់ពាក់កណ្តាល Demi-cercle) ដែលមានន័យថា អនិច្ច (Impermanence) នៃវត្ថុទាំងអស់ក្នុងលោក ។ ស្តូប គេច្រើនសង់នៅលើខឿនខ្ពស់ល្មម មានរបងព័ទ្ធជុំវិញ ។

## ៤- ចេតិយ

ចេតិយ ច្រើនមានកន់ ៤ ជ្រុង ឬ កន់មូល បិតត្រួតលើគ្នា ជាជាន់ថ្នាក់ ៗ ធាតក្រោមរីកធំ ហើយរៀវតូចបន្តិចម្ដងៗ រហូតដល់កំពូល មានកន់ជាច្រើនថ្នាក់ ៗ តាមធម្មតាគេតែងសាងចេតិយ ឱ្យមានបីថ្នាក់ ដែលមានន័យតំណាងព្រះរតនត្រ័យ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។

ចេតិយ ក្នុងពុទ្ធសាសនា មាន ៤ បែប គឺៈ

ក) ធាតុចេតិយ – ចេតិយសម្រាប់តម្កល់ ដាក់ ឬ បញ្ចុះអដ្ឋិធាតុ ព្រះពុទ្ធ ឬ មាតាបិតា ជាដើម ។

ខ) បរិភោគចេតិយ – ចេតិយសម្រាប់ដាក់វត្ថុប្រើប្រាស់របស់ព្រះពុទ្ធ មានវត្ថុពុទ្ធទនិតម្រង់ទឹកជាដើម ។

គ) ធម្មចេតិយ – ចេតិយ សម្រាប់តម្កល់ក្បួនច្បាប់ សាស្ត្រា គម្ពីរ ពុទ្ធវចនៈ មានព្រះត្រៃបិដក ជាដើម (បុរាណ: ហោត្រៃ) ។

ឃ) ឧទ្ទេសិកចេតិយ – ចេតិយឧទ្ទិស ថ្វាយ បូជាចំពោះ

ព្រះពុទ្ធ ព្រះរតនត្រ័យ ឬ អ្នកមានគុណ មានមាតាបិតា គ្រូ ឧបជ្ឈាយ៍ ជាដើម ។

## ៥- វិហារ Vihàra (Temple)

ព្រះវិហារ ឬ ឧបោសថាគារ ជាកន្លែងសម្រាប់តម្កល់ព្រះបដិមាករ ដែលមានមួយព្រះអង្គធំជាងគេ មិនជាកន្លែងសម្រាប់ព្រះសង្ឃធ្វើសង្ឃកម្មផ្សេង ៗ មានឧបោសថកម្ម ឧបសម្បទាកម្ម ជាដើម ។ វិហារតាំងនៅចំកណ្ដាលវត្ត នៅលើខឿនខ្ពស់ ៗ វិហារទាំងអស់ សុទ្ធតែបែរមុខ ឆ្ពោះទៅទិសខាងកើត ដែលតំណាងទិស ព្រះពុទ្ធត្រាស់ដឹង ក្រោមដើមពោធិព្រឹក្ស បែរព្រះភក្ត្រទៅទិសខាងកើត ។

ព្រះពុទ្ធរូបបដិមាករ អង្គធំ ដែលគេតម្កល់នៅលើបល្ល័ង្កខ្ពស់ ក្នុងវិហារ មាននាមថា «ព្រះជីវ៍» ។

## យ – អក្សរសិល្ប៍ Littérature

រឿងរ៉ាវ អត្ថបទអក្សរសិល្ប៍ ជាច្រើន , អ្នកនិពន្ធ

បានដកស្រង់ចេញមកពីគម្ពីរ ក្នុងពុទ្ធសាសនា ពោលគឺ ព្រះត្រៃបិដក និងគម្ពីរអដ្ឋកថា ធម្មបទ វិសុទ្ធិមគ្គ មង្គលទីបនី ទសជាតក៍ និង បញ្ញាសជាតក ជាដើម មកតបតែងចងក្រងជាស្នាដៃរបស់ខ្លួន ។ អក្សរសិល្ប៍ បែបនេះ ជាចលនា ពុទ្ធនិយម ដែលបានលើកយកសកម្មភាពពោធិសត្វក្នុងការកសាងបារមី ឬដែលបានលើកយកទស្សនៈសំខាន់ក្នុងពុទ្ធសាសនា ពោលបញ្ហាកម្មផល បុណ្យ បាប ជាដើម មកពន្យល់ អធិប្បាយ តុបតែង ។

អក្សរសិល្ប៍ ចលនាពុទ្ធនិយម អាចចែកជា ២ ប្រភេទ គឺ:

១- អក្សរសិល្ប៍ តំណាងចលនាពុទ្ធនិយម ពិតៗ ដែលអ្នកនិពន្ធ បានដកស្រង់ចេញមកពី ទសជាតក

- តេមិយជាតក បំពេញ នេក្ខម្មបារមី
- ជនកជាតក " វិរិយបារមី
- សុវណ្ណសាមជាតក " មេត្តាបារមី

- ទេមិយជាតក បំពេញ អធិដ្ឋានបារមី
- មហោសថជាតក " បញ្ញាបារមី
- ភូរិទត្តជាតក " សីលបារមី
- ចន្ទកុមារជាតក " ខន្តិបារមី
- នារទជាតក " ឧបេក្ខាបារមី
- វិធុរបណ្ឌិត " សច្ចបារមី
- វេស្សន្តរជាតក " ទានបារមី

២-អក្សរសិល្ប៍ តំណាងចលនាពុទ្ធនិយមក្រោយ ដែលអ្នកនិពន្ធបានដកស្រង់ចេញមកពីគម្ពីរ បញ្ញាសជាតក ជាគម្ពីរអដ្ឋកថា កើតមានឡើងនៅប្រទេសលាវ ក្រុងឈៀង-ម៉ៃ ប្រហែល ៥០០ ឆ្នាំ ប៉ុណ្ណោះ ។

អក្សរសិល្ប៍បែបនេះ មាន:

- រឿង សុភមិត្រ - រឿង កោតុលកុមារ
- រឿង ព្រះសុធន - " លោកនេយ្យជាតក

- រឿង ព្រះសមុទ្រ — រឿង វិមានចន្ទ
- ,, សព្វសិទ្ធ — ,, ស្រទបចេក
- ,, មរណមាតា
- ,, ខ្យង់សង្ខ ។ល។

* * *